"Roeung" "Neang chompathong"
ឝ-៤៩-៧-៣៩៧

# រឿងនាងចំប៉ាថោង ២



B-3
D-86
N-2973
ទ-ទ
110

1953 - 6



B. 31 - 235 86

ស្ដេចតែងគន់មើល សព្វផ្កាម្លប់ឈើ ទំនាបទួលទី
ផ្អូតផ្អេះអាឡោះ ស្រណោះប្អូនស្រី ក្រឹកក្រលួឥតបី
ល្ហៃល្ហើយសោកា ៗ ស្ដេចឲ្យសេនីយ ដើរដោយព្រឹក្សព្រៃ
រុករកកញ្ញា ក្រែងបានពេបពះ ប្រទះនេត្រា
ខ្លាចក្រែងធិតា វង្វេងមាគ៌ា ៗ សេនារត់រក
ព្រះប្អូនពន្ទុក សព្វស្ថាននានា ទន្ទ្រានកាត់ទៅ
សំដៅទិសា សិងហុនភាព រឹងរូតកន្ទួង ៗ
ឯព្រះភូធរ គង់គុជ្ឈនបវរ ខ្ញីឃ្នាតដោយដង
ប្រាំពីរខែ ក្រត្រាបប្រះប្រង ពុំយល់ឡើយហោង
រឹងទៀនសេនា ៗ កាលណោះជួនយប់ សែងសូត្រឡប់
ងងិតមហិមា ហេតុដែតភូមី ពុំពិចារណា
ផ្ញើទោសជាយា ឲ្យទល់ទុក្ខក្រៃ ៗ បាបនោះទាន់ហន់
ហៅបច្ចុប្បន្ន ពុំលង់ឡើយនៃ ឲ្យអស់យោធា
សេនាទីទៃ វង្វេងផ្លូវព្រៃ ពុំដឹងទិសទី ៗ
ទាំងក្សត្រទាំងពល ដេងដោងវិលវល់ វិមរាមវក់វី
សូន្យសុងគយគន់ តំបន់គិរី ពុំយល់ធានី
រឹងធ្លល់មហិមា ៗ ខ្វះគគក់ទ្រូង ដៃដាក់លើត្បូង
អង្វរទេវតា មើលមុខអាក្រក់ ស្ងើតស្ងក់នេត្រា
ញើសក្អែលហូរហៀរ កំខៀវខំក្រៃ ៗ យល់តែស្បូវស្បាត

បន្ទាញឹកញៀត　សាញសឹងព្រឹក្សព្រៃ　បង្អៀតជៀតជែក
លាស់មែកត្រឈៃ　ព្រួញព្រួយចិត្តក្រៃ　នឿយណាស់គ្រប់គ្នា ៗ
ឯអង្គកូមិន　ដៃដេតបក្រិន　ព្រួយព្រះចិន្តា
រងិគិតរងិធ្ងល់　ពុំយល់មាតា　ហេតុអ្វីប្នេះណា
ឲ្យអស្ចារ្យក្រៃ ៗ　ស្ដេចគិតទៅដល់　ព្រះប្អូននិមល
រិតរឹងអាឡៃ　មិនមានហៅសុខ　ផ្អុក ៗ ព្រះទ័យ
ឆេងឆោងសន្ទៃ　ក្រិកក្រួលថ្ងៃថា ៗ　ឱអញសង្វាត
ផ្ដាច់ជនជាតិ　ស្វះស្វែងយាត្រា　ស្មានទឹងបានយល់
ដូចកលប្រាថ្នា　មិនដឹងរងជា　ឃ្លាតទៅឆ្ងាយក្រៃ ៗ
ឱអញសូវស្លាប់　រស់នូវអាកត្យ　ព្រាត់ព្រះប្អូនស្រី
ម្ដេះសំខុសខាន　ពុំបានមូលមៃ　ត្រិះត្រេកហឫទ័យ
ដូចដើមនោះណា ៗ　ឱទៅពន្ទុក　បងរុកពានរក
មាសមិត្តពិងា　បាបអ្វីវង្វេង　ជវៃញ្ញងឲ្យជា
ទុក្ខទោមនស្ស　ពេកពន់ពុំស្បើយ ៗ　ឱមាសឧត្តម
មេបាកបោលចំ　បែងបាត់ព្រងើយ　ពុំនឹកស្នេហា
កាលគ្រាដើមឡើយ　ឱសំឡាញ់អើយ　បងជាទុក្ខក្រៃ ៗ
បងពុំដឹងដើរ　វង្វេងង្វេសង្វើ　កណ្ដាលព្រឹក្សព្រៃ
ទុរគមឥតបើ　នឹងធ្វើម្ដេចនៃ　បានយល់ស្រីថ្លៃ
សោះទល់ទុក្ខា ៗ　បើពុំបានយល់　រូបរតនិមល

ស្លាបឯមរនា មិនទើងវិលថ្កាន ទីស្ថានឡើយណា
តាមទៅលុះត្រា អស់ជន្មជីវ ៗ នៃនិទាននេះ
ទឹងបង់អងស្មុះ ពិតពុំស្រដី យើងទឹងថ្វាថ្លែង
សំដែងអំពី ហេមន្តបុរី គេការឈ្មោះនៃ ៗ
បរិពារព្រះស្នំ ស្រីគ្គាចាស់ទុំ ស្នំស្និតសៅដៃ
ក្រោយនាងទោះធ្លាក ចរបាកឃ្លាឃ្លៃ សឹងសោកអាឡៃ
ទួញយុំត្រប់គ្នា ៗ ខ្សិបខ្សៀវស្អាស្អក ផលនេត្រស្រោចស្រក់
ប្ដីទឹងការិយា នូវអស់មន្ត្រី សេទីផងគ្នា
រុះគិតទឹងយាត ត្រាតាមទេវី ៗ ព្រមស្រេចស្រើបស្រុស
ពុំលុងការឈ្មោះ ដួបចូលពត្រី រៀបមែកកញ្ចើ
ទូលលើសិរសី រួតរត់ចេញខ្ចី ចុះចាកត្រឹះហា ៗ
ពារកូនពារចៅ ត្រេបត្រង់សំដៅ សឹងហុនភារ
ពុំគិតព្រួយប្រាណ ហេតុមានចិន្តា អាឡៃដេយព្រា
ប្រសើរស្រស់ស្រី ៗ រួតរះពុំឈប់ ទាំងថ្ងៃទាំងយប់
លុះខែមួយខ្ចី ដើរដល់សែមា យកព្រធិបតី
បរបូលវន្ទី នាងនាថថ្ងៃថ្វា ៗ ខ្វះក្រាបទួញយំ
ខ្វះយកដៃដំ គគក់ឪក ខ្វះស្រែកទ្រហោ
ឆោឡោសោកា ព្រះមាសពាំភ័ក្រ ព្រាត់យើងយូរលង់ ៗ
ខ្ញុំចប់ក្ដាត់ណា កាលស្ដេចយាត្រា ចាកចំបែងបង់

សំនឹងលំបាក ចរចោគឯកអគ្គ កិតកៃឡែនឡើង
ដោយព្រៃព្រឹក្សា ៗ ជប់ហើយជប់សល់ ក្រែនក្រប្បានដល់
បុរីផ្កា សាឡៃតុំភ្លេច ដល់ដេចទេវា
ហេតុនេះខ្ញុំយា ត្រាគាមមកហោង ៗ ស្រីស្រស់ឧត្តម
នាងយល់ព្រះស្នំ ទួញទូលអឹងកង នាងបើកព្រះសូរ
បន្ទូលសាសង អាសូរគ្នាត់ហោង ៖ហេតុមានស្នេហា ៗ
តុំគិតព្រួយប្រាន មុះមកលុះបាន ដល់ដូចប្រាថ្នា
ឧអញអរក្តាត់ កោតចិត្តអស់គ្នា ស្ងួនស្ងួនយាត្រា
ផល់ដម្បូន់កាយ ៗ ក្សត្រីនិមល សាកសួរទៅដល់
ក្សត្រពីរពន្លាយ ទូវព្រះវៀមរក្ខ ស្ដេចសុំតទូវនាយ
គ្រៀមក្សត្រនសប្បាយ សុខសួរកុំ ៗ ប្ដូមួយក្រែងមាន
ល្វើយុកតុំក្បាន ចូរប្រាប់ដោយដំ ណើរនឹងចង់ស្ដាប់
សាស័ប្លកូវកុំ លាក់ឡើយសោតសំ តែពាក្យផែលពិត ៗ
ឯអស់ព្រះស្នំ ឧទអគ្គបគ្គិ កកាយដួញដិត
ទើបទូលទៅថា មាតាស្នំស្និត ព្រួយព្រះទ័យក្តាត់
ក្រោយព្រះយាត្រា ៗ តាំងព្រះដំនុក សន្រែងរងទុក្ខ
សព្វទិនទិវា តាំងបីព្រះអគ្គ ត្រេចត្រង់យាត្រា
រកកដធីតា ដោយសព្វទិសទី ៗ ព្រះវៀមសោតនៃ
ព្រួយព្រះហប្ញទ័យ សម្ដេចភូមី ទ្រង់ព្រះកន្សែង

ឯកឯងសែនថ្លី អត់អាហារកិ ណាចលទ់មហិមា ៗ
សរ្រេនរន់ទុក្ខ ពិតពុំមានសុខ ក្នុងព្រះទេយ្យា
រសាប់រសល់ ចង់យល់កត្រា អ្នកមាសពំនា
ចាកចេញបង់បាត់ ៗ ប្រសិនយូរលុន ពេកពុំយល់អង្គ
ដាលដល់ជាថ្កាត់ ដោយក្តីស្នេហា មេត្តាស្រីរត្ន ថ្ងោះហើយខ្លោយក្តាត់
ដោយគេមោសា ៗ នាងស្តាប់សំដី ពាក្យតីទាសី
ទូលដូច្នោះណា នាងរិងគន់គិត អាណិតក្សត្រា
ដោរផលផាព សស្រាក់ហូរល្ហន ៗ ហើយនាងទាថទៅ
ទូលព្រះបោមទៅ បិតាសូមឈ្នួន ដ្បិតស្រីស្រីគ្នា
បរិពារខ្ញុំឯង រួតរត់លះលែង ហេមន្តកាក ៗ
នាំទាំងកូនទៅ ប៉ុនប៉ងមកនៅ ជាខ្ញុំបាទា
ពុំបេរព្រះអង្គ សូមទ្រង់ករុណា អាសូរដ្បិតក៏
ស្រីឡាញ់ខ្ញុំសល់ ៗ ហើយនាងទូលតី ក្សត្រក្សត្តទាំងបី
ស្តេចរងទុក្ខទល់ ឯអង្គយក្ស បីតាទសពល
ស្តាប់នាងនិមល ទូលទើបក្សត្រា ៗ ស្តេចទ្រង់ព្រះក្សត្ត
ទ្រង់ព្រះរាជទាន ទ្រព្យផងនានា ឲ្យអស់ទាំងស្រី
ទាសីនោះណា ក្រៀមក្សត្តសុខសា បាយបុណ្យភូមិ ៗ
កាឈ្មោះពុំលុង គេជះព្រះពង្ស ពុទ្ធស្រជិនស្រី
កក្រើកអាស្នា ឥន្ទ្រាកោសី បើកទិព្វចក្ខុ

យល់ពន្ធុរស ដោយនេត្រសហា ហៅពិស្នុកា
បើកបន្ទូលផ្ដោះ ចូរបាចរថ្កាន ទៅនាស្ថានមនុស្ស
រចនាចំពោះ ប្រាសាទសោភី ៗ ឲ្យព្រះន្រាយ
ធីបេះធាមធាយ ពូជពន្ធ្យព្រោះធី ពិស្នុកាស្ដាប់
សាស័ប្បកាសី ផ្ទុកផ្ទោះបុះខ្ចី ដល់ដៃនកស្យធា ៗ
និមិត្តកំផែង ទូលាយឃ្វាត់ខ្វែង ប្រាំពីរជាន់ជា
បានក្បានបន្ទាយ ធើតឆាយក្ដឹថ្លា កែវកែមសុវណ្ណា
ត្រជួបជោមឆ្ងាយ ៗ ឯកន្ទាំងខណ្ឌ ផ្កាយផ្សប់ទូរចន្ទ
ឆាយាពន្រាយ ពេន្ធរប៉ាំយាម តែងតាមសួគិនាយ
ក្សូរក្បាច់លេចលាយ ត្របកបូផា ៗ មានពេន្ធដំរី
ពេន្ធរតពាជី ឳសុថមហិន្ទ្រា ប្រដាប់កែវកែម
លាក់លែមសោភា ពេន្ធទន្ទ្រកឡា ស្រិគ្កាគំនាល ៗ
ពិសេសបទុំ ផ្សផ្សប់ផ្ទួរចម ទៅបូរវៀនពល់
ដំលូយទទឹង ទ្រឈឹងឆាឆាយ ល្អល្អះពព្រាយ
ក្ដីផ្ទុកសោះសា ៗ ជាន់ក្រៅប្រាសាទ ខ្ពង់ខ្ពស់ស្អាងស្អាត
ស្រោងស្រួចមហិមា មុខព្រហ្មតែស្ទូរ កំពូលដីពរ
ជង្គានានា រូបរស់វិសេ ៗ សរសេរសឹងពេជ្រ
ដាក់ដាំរំលេច ទទិមទិព្វថ្ម ដញ្ចាំងស្វរិការ
មែនមានដម្មៃ ក្រាលក្រោមនោះនៃ បរណៃក្ដីថ្លា ៗ

ពិទាយទឹកវិល ធ្លុកធ្លុះនូវទិល កណ្ដៀនមុក្ខា
ដម្រាផែន ៗ ហើយស្រេចជាក្ដា ជាន់ជៅធ្វើជា
គ្រឿងគ្រប់សោតហោង ៗ ពុំមានយកឈើ បុច្ចមកធ្វើ
ថ្វាយព្រះបរ្យះបរ្យង សុទ្ធសឹងសុវណ្ណ សោភ័នឥតហ្មង
នូវមណីរត្នផង រំលេចគ្រប់ទ្វារ ៗ ស្រេពទើបធ្លាតធ្លុក
កែមក្បាយល្បេចល្បក ក្បាច់ក្បូរក៏ផ្កា ធ្លាក់នៅកិដាន
ហើយមានកុម្ភ មាសមុខគ្រិបផ្កា កិដាននោះនៃ ៗ
ធ្លាក់ជាម្ទីពាន់ ម្ទីរតល្អលន់ ប្រពត់ឯកញ្ញ
ធ្លាក់ជាស្រីសួគ៌ គាប់គួរល្ហមល្ហៃ ធ្លាក់ជាទេពថ្វៃ
ហិចហោះវិហា. ៗ ធ្លាក់ជារូបសឹង ឈរឈប់ប្រាណប្រឹង
ស្ពាញស្ពប់ប្រាព ចំងចំអើត ស្ទក់ស្ទើតនេត្រា
ពហុទន្តា សរស្រាញស្រើបក្រៃ ៗ ធ្លាក់ជាក្រពើ
ហែបហែលលលើ នាគន្ធដលសៃ ធ្លាក់ជាពិនទង
ត្រសង់ស្កិមស្កែ ធ្លាក់ជានាគនៃ ប្រខាំនឹងម្ករ ៗ
ធ្លាក់ជានាគី នាំក្រិសផុសព័ កណ្ដាលសាគរ
ធ្លាក់ជាដំរី ឃ្មាតខ្មីងើយង បោកបក់បំាម
ផាយផាត់គគ្គារ ៗ មានទាំងកំពាន់ ពិជ្រាជរកាន់
ដំបង់សោះសា ដាត់ធំស្រឡះ កាន់ព្រះការតា
គ្រន្ទួននេត្រា បង្កួមសរស្វាប ៗ ធ្លាក់ជាគ្រុឌា

ឆាបឆក់នាគ្គា ដោយតេជះអំណាច ធ្លាក់ជាកិន្នរ
បវរឯងអាច រេកំណើតដ តិរបុត្តា ៗ
ហើយមាននូវកាល បព្រឹក្សផុសផាល ទាំង៤នោះណា
ដោយដ្រុងប្រាសាទ ស្អាងស្អាតសោភា តាមតែចិន្តា
នឹកគិតបង់បាន ៗ មាននាងកញ្ញា ស្រីទេព្វសួគ៌ា
ល្អល្អះកល្យាណា នូវអស់សម្រាប់ ប្រដាប់សឹងមាន
មិនខ្វះក្នុងស្ថាន មុណីសុវណ្ណា ៗ សូរេចបរិបូរ
ពិតពុំលុងយូរ ព្រះពិស្នុកា ស្ដេចវិលសួគ៌ស្ថាន
កិមានអាត្មា ធ្វើអក្សរជា សំគាល់ទុកនៅ ៗ
លុងលុះសុរិយា ស្រេចស្រាងបូរពា ព្រហ៊ាមប្រាលផ្តៅ
កាល្ហោះអស់យក្ស ភ្ញាភ្ញាក់មើលទៅ យល់ហើយហៅកៅ
អរអឺងគ្រប់គ្នា ៗ អ្នកខ្វះថាយើ ប្រាសាទនេះតើ
ស្ថានអ្នកឯណា សព្វថ្ងៃមិនយល់ អញឆ្ងល់មហិមា
ថ្ងៃនេះយល់ជា អស្ចារ្យពេកក្រៃ ៗ យក្សផ្អើលរបល
មកមើលមណ្ឌល ប្រាសាទមាសមៃ ក្រញែងសិរសា
អ្នកណាបុណ្យក្រៃ នេះគឺទេព្វថ្ងៃ និមិត្តមកថ្វាយ ៗ
ព្រះពជបុត្រា នាងសុវណ្ណា រឹងរិទ្ធិសាយ
មិនគឺមនុស្សលោក ថយថោកពាយឆាយ បុណ្យម្ដេចអំបាយ
លើសលើលោកា ៗ ខ្វះរត់ទៅទូល ព្រះបាទឥសូរ

សឹងហុនយក្សា ស្ដេចជ្រាបសេចក្ដី ពាក្យពីសេណា
ក្សិនក្សត្រយាត្រា ដល់ដូចបំណាន ៗ ស្ដេចទតយល់យុន
ត្រីត្រពួបអស់អង្គ ស្ងប់ស្ងែងកន្ទួង ក្រវីសិរសា
ក្សត្រាទ្រើសគ្នង ទតទិស្ដានផង ពុំផ្អែតបិទ្ធា ៗ
ស្ដេចដើរចូលដល់ មើលមាត់ទ្វារយល់ សឹងមានអក្ខរា
ជ្រាបដោយសេចក្ដី កោសីរចនា លុះលាន់មាត់ថា
ឱព្រះជនតោ ៗ បុណ្យពេញត្រកាល ក្រៃលែងកពកា
នគរឯកទោ ចាំងហានព្រះឥន្ទ ទេវិទសក្កា
ស្ពួតិសោតចាំងសោ ឲ្យសលើនាយនៃ ៗ ពិតពុំរលង
លើសលើនេះម្ដង គួរគួរស្មើដៃ ទឹងអស់ជំនាង
ស្អាងស្អាតប្រពៃ បុណ្យបារមីក្រៃ ក្រទឹងគណនា ៗ
ហើយឲ្យយក្សយុង ទៅហៅអស់អង្គ មន្ត្រីយក្សា
មកហើយបន្ទូល មធុរថ្លែងថា ហៅអស់ចាំងគ្នា
យក្ខយើងទាំងឡាយ ៗ ស្រពទម្មីមា ប្រាមប្រាប់គ្នីគ្នា
ទោះពលទោះនាយ ប្រដាប់ប្រដា ឲសក្រាខ្វល់ខ្វាយ
រៀបរត្ដាប់ថ្វាយ ភជនរសក្រា ៗ ឡើងគង់ប្រាសាទ
ប្រសើរស្អាងស្អាត កុំលុងឡើយណា អស់យក្សយុងស្ដាប់
សាស័ព្ទភចា ត្រូតរត់យាត្រា ប្រាមប្រាប់រំពង ៗ
ឯអង្គសេនា ត្បូព្រះកាថ្វា ក្សត្រក្រានប្បុះប្បង

រៀបដោយក្នាក់ឆា　កាន់ការរាប់រង　ប៉ារម្ភក្រែងធ្គង
ទោសផល់អាត្មា ៗ　ស្រាប់ស្រេចបរិបូរ　ពិតពុំលុងយូរ
បានជួបអាជ្ញា　ចំរៀងរបាំ　រៀបចាំវិលា
ទូនទូងដៃជា　ចាំម៉ាសរផ្អៅ ៗ　ធ័ត្រែធាយាកាន់
ក្ងឹងក្ងស់បើកបាំង　ដាផ្លូវរៀងទៅ　ទាល់ទីស្ថានស្ថិត
ប្រកិតនិតនៅ　យក្សយុងហោហៅ　កកាន់ដោយដៃ ៗ
សែនថ្វាន់បាយមន្ត　សូរសេពនូវផន់　ត្រីត្រែស្រឡៃ
ពិនពាត់គងកាន់　កំណាន់ទីទៃ　ខ្នាន់ខ្នាប់ឯឮ
ព្រះហោនក្សត្រា ៗ　ស្គរទ័ពស្គរទូង　ស្គរអត់អន្ទូង
អត់បព្វាប់មហឹន្យា　ចាប៉ី ៗ អរ　ត្រុតទ្រភ្លេងផ្លា
ភ្លេងបិនស្គរហ៊ា　សំភោពាធម៉ាង ៗ　ឯសុវណ្ណា
ប្រដាប់អាត្មា　ទ្រង់ព្រះសំអាង　នូវអស់ធីតា

កញ្ញានៃបនាង ស្អិតស្អាងរូបរាង ដោយគួរទីទៃ ៗ ខ្វះស្លៀកប័យតង
មុខមូលបំព្រង　ល្ហោសល្ងន់ប្រពៃ　ដន្ទប់ស្ពានខៀវ
ជុំលៀវល្មមល្មៃ　ធៀងឈ្មងប៉ៃប្រែ　ប៉ប្រិមទស្សា ៗ
ខ្វះស្លៀកស្ពានស្វាយ　ប៉ានប៉ាក់ដជាយ　ផូវផង់អស្ចារ្យ
ដន្ទប់លើងទុំ　សោភតសំកន្ត្រា　ថ្ពាល់ដូចផល្វា
មាក់ប្រាងមាសមៃ ៗ　នាងខ្វះដន្ទប់　ដំពូចំប្រប់
ដូចចងរៃប　សែសយលាយលេច　ស្រស់ស្រេចល្អក្រែ

ស្លៀកសំពត់ផ្លែ  មេឃមាសជាយផុំ ៗ  ខ្លះស្លៀកស្ពានខៀវ
ស្លៀកល្បើកផ្មិនខ្មៅ  ទឹកមាសបំព្រង  ដន្តប់ស្បៃច្រាល
រន្ទាលអស់អង្គ  សម្បុរខ្មៅយង់  ខឹមខាត់គន្លា ៗ
ខ្លះស្លៀកមង្គ្រើវ  ដណ្តប់ស្បៃខៀវ  លំញងកក្រា
សមជាអ្នកក្ទង  ទដុងថ្ងៃថ្ងា  ញញឹមបរបារ
សើចសំៗដី ៗ  ដោះក្បំបង្ទៀត  បុកម្ចូត្រនៀត
កាយកល្យាណី  ពាលពេញក្រមុំ  ទើបពុំបារី
បានបទហាក់ស្រី  ក្រមុំអ្នកលើ ៗ  ខ្ជាប់ខ្ជួនរិកពារ
ពិតពុំស្រើបស្រាល  ថ្ងិបថ្ងំពើ  សុភាពធ្ងន់ធ្ង
ទឹងទរតតស្ទើ  មិនមានសើរើ  ពាក្យពេចន៍រាបា ៗ
ផ្គូផ្គងឲ្យគាន់  សឹងជាកំណាន់  ហៃវរជ័យ្យា
កាន់ពានព្រះពស  ស្រិលស្រស់សោភា  ខ្លះកាន់គន្លា
វិសេសតែងទ្រង់ ៗ  កាន់ពានព្រះស្រី  ព្រះវិជ្ជនី
រូបល្អវរវង្ស  សិតសៀតកេស្រា  មាលាបញ្ចង់
បញ្ចើអស់អង្គ  ល្អៗដូចគ្នា ៗ  ខ្លះកានព្រះឆាយ
បន្ទាយចុងជាយ  ស្បៃស្បិតយាត្រា  នាងមួញមិញល្អ
ឲ្យពារិឡា  ទុនកុនកាយា  ស្រគុតហ្មត់ហ្មង ៗ
លុះបានវេលា  ស្រីស្រស់សោភា  នាងបរបេញផ្គង
គង់លើយានថ្ងៃ  ប្រៃពេប្បាស់ប្បង  ពបុត្រស្នែស្នង

ដួញផិតអគ្គា ៗ ស័ព្ទត្រែសាំងសំ ពិនពាធដេញដំ

រងុំឈូនា ទទូងគរ តន្ត្រីព្រមគ្នា

លាន់ឮមហិមា គគ្រេងក្រេងក្ទាត់ ៗ នាងត្រេចទៅបាន

ដល់ប្រាសាទហាន បរបាកយានយាត ត្រាត្រេចគួរគង់

នាគង្គប្រាសាទ សំសោភាស្អាត នឹងបុត្រស្នេស្នង ៗ

ព្រាហ្មព្រឹធគរី សូត្រសែពស្មុតដី អរឲ្យពរគង់

បំរើនព្រះស្រី ក្សត្រីឥតគ្គង នូវបុត្រសួនក្រង

ប្រាំពីរខេព ៗ ហើយលេងម្ហូស្រព បរិបូរគ្រាន់គ្រប់

សូរេចហើយណា នាងនៅនឹងបុត្រ ពិសុទ្ធស្នេហា

ទាសីទាសា គង់គាល់សព្វថ្ងៃ ៗ ហើយនាងបរបេញ

ទៅទតជុំវិញ មណ្ឌលនោះនៃ ទតផ្កាបុព្រឹក្ស

ស្រោមស្លឹកប្រពៃ គាប់ក្នុងព្រះទៃ គ្មានទាស់ត្រង់ណា ៗ

នាងនៅសព្វថ្ងៃ ផ្អកផ្អើសភាទៃ្ស ព្រះវៀមកជា

ស្ងៀមពុំហ៊ានបែង ថ្វាងថ្វូងបរតា ខ្លាចព្រះបីតា

ប្រាបហើយក្រែងគ្គង ៗ លុះលុងទៅក្ដាត់ ព្រះពោធិសត្វ

រាជបុត្រប្បះប្បន់ បំរើជនសា សោភាឥតហ្មង

ឆ្នាំបះហើយហោង ទ្រង់ឆោមឆាយា ៗ ស្ដេចតែងទៅគាល់

ឮយុំកោទ្រង់ធម៌ សព្វទិន្នទេវ៉ា ស្ដេចទ្រង់ព្រះក្សាន

មែនមានករុណា ព្រះរាជកុមារ ពិតពុំឲ្យឆ្គង ៗ

ស្តេចឲ្យស្រិតស្រាល ស្រិទាំងកម្សាល កូនមន្ត្រីផង
នូវកូនព្រះវង្ស រាជវង្សស្នេស្នង មួយពាន់គោគហោង
ប្រានប្រុសសោភា ៗ សឹងជាសេណី បំរើប្រកតី
សព្វថ្ងៃត្រៀបត្រា ក្សត្រយក្នុងចោមចៅ ប្រដៅក្សត្រា
រួសរៀនឧស្សា ចប់ត្រៃភេទផង ៗ ហើយព្រះពុទ្ធពង្ស
ស្តែងស្តេចតែងទ្រង់ ធុរសីលសរផង ពុលានវិហារ
ឯអាកាសគង់ ទើបទេវផង សប់ស្ងៃវិត្វា ៗ
ព្រះព្ធយគោ យល់ដូនគោ ទ្រើសទ្រង់សរថ្វា
ពេញព្រះទ័យឯង ក្រវាញសិរសា គោគព្រះបេស្តា
នរសេត្ថថ្ងៃ ៗ ហើយក្រុងអាសុក ឲ្យសង់ព្រះបទ្វា
ប្រប់ឆ្នេរផលសៃ ស្រះស្រង់ផាបាន គុជ្យានប្រពៃ
ផាំផល់ផក់ម៉ៃ ប្រើនពណ៌នា ។ ៗ រព្រះពន្លាយ
ធីបេតធោមធាយ ពន្ធុកសាស្តា ស្តេចតែងប្រពាធ
ពុំខានទេវ មួយឡើយសឹងជា និវន្ទវង្សហោង ៗ
លុះព្រះសុរិយា ស្រទន់ហើយណា ទើបស្តេចវិលគ្គង
គុនអគ្គអក្ក ដិទីច្បះច្បង នាងបរិត្រកង
ថើបអស់អគ្គា ៗ ទតសព្វសារពាន ផលនៃត្រៃលោង
ពុំចេញចរចារ គិតជាគុបុត្រ សាចស្មួតប៊ីតា
ម្តាយយល់មុខបា វិះវិធថប់ក្រៃ ៗ ព្រះពោធិសត្វ

| | | |
|---|---|---|
| ប្រណម្យទូលថ្វាត់ | ឋ្កានមាតាថ្លៃ | សូមទានមេត្តាអ្នក |
| អន់អាក់ព្រះទ័យ | ផលនេត្រល្ហងល្ហៃ | ហេតុអ្វីម្នះណា ៗ |
| ឯព្រះជិនី | ស្ដាប់ព្រះពោធី | សាសងឆ្លើយថា |
| ក្សត្រីវរវង្ស | នាងទ្រង់ចិន្តា | មិនឱ្យបុត្រា |
| ដឹងដើមព្រះទ័យ ៗ | កែងជ្រាបទៅដល់ | បិតាទសពល |
| នូវទុក្ខក្រោធក្រៃ | នាងគិតថាម្នោះ | ដោយដោះថាហៃ |
| កូនស្ងួនថើមថ្លៃ | បណ្ដូលស្នេហា ៗ | កូនអើយសម្រាម |
| ផ្កាក់បូលរកា | រង្កៀសនេត្រា | ទើបយកបានចេញ |
| អម្បាញ់មិញណា | អង្គីមិនជា | ហេតុអ្វីឡើយហោង ៗ |
| ឯទីរសថ្លៃ | ស្ងានស្ងោះស្ងូរម៉ែ | ជឿជាក់ជាមួង |
| ពុំដឹងព្រះមេ | ស្រាយស្រែលាកលង | ពុំជ្រាបទំនង |
| ពីព្រះបិតា ៗ | ហើយស្ដេចតែងទៅ | គាល់ព្រះបោមបៅ |
| ព្ទយុគោយក្យ | ស្ដែងស្ដេចចុះឋ្កាន | ទីឋានពន្ធ |
| សព្វ ៗ ទេព | ពាំលោះឡើយហោង ៗ | ឃើញនូវស្រដី |
| ឯអង្គព្រះបី | គាត្រេចដោយដង | ពុំយល់មាគា |
| ក្សត្រាបង្សះបង្សង | សន្រេងវិង់វង់ | ទុក្ខទ្ទញសោកា ៗ |
| ក្សិកក្សួលថប់ថៃ | ពិតពុំមានល្ហៃ | សព្វទិនទេព |
| ស្ដេចលើកទសក | អន្ទរន្ទា | ទេពឆកាមា |
| សោឡសសួគិថ្លៃ ៗ | សូមអ្នកករុណា | បង្ហាញមាគា |

ខ្ញុំកាលនេះនៃ ឲ្យបរិបូរបាន ក្សេមក្សាន្តភ័យ
យល់នាងនាថថ្ងៃ ដូចចិត្តប្រាថ្នា ៗ ផ្សង់ហើយអួលអាក់
ព្រះនេត្រសស្រោក ហូរហែតស្នេហា ស្រយុតស្រយង់
អស់អគ្គក្សត្រា សៀមស្ងាត់វាចា ពុំចេញសូរសង ៗ
ឯអស់មន្ត្រី ដែលនាមចក្រី ទាំងអម្បាលផង
យល់ស្តេចសោកា អាមោកក្តាត់ហោង វិងរូតកន្ទុង
រត់រកមាគ៌ា ៗ ដើរខុសវិលវល់ សូន្យសោះពុំយល់
ដម្បូទ់ទិសា នឿយណាស់ល្ហិតល្ហៃ ទីទៃគ្រប់គ្នា
ប្រាស់ប្រាននិទ្រា ដួលដេកសព្វឋាន ៗ អស់ជើងរពាយ
ដួលដូចគេពាយ រៀងព្រៃសាសាន ខ្វះឈរត្រមឹង
សម្រិងសម្រាន ខ្វះខ្វាំងដើរបាន ទាន់ទៀបពជា ៗ
អត់បាយឥតបើ ស៊ីតែផ្លែឈើ តាងភោជនាហារ
ខ្វះស្រែកខ្វះយុំ ដៃដំទឹក នឿយណាស់មិនត្រា
យុងយល់ផ្លូវឆ្ងាយ ៗ កម្ពុងយូរក្តាត់ បីឆ្នាំទៀងទាត់
ទើបព្រះពន្លាយ ស្តេចដើរមកត្រូវ ត្រង់ផ្លូវទូលាយ
ទទួលសប្បាយ ដែលនាំដេយ្យា ៗ ស្តេចយុងយល់ជាក់
ព្រួចព្រឺព្រះភក្ត្រ អវេតតគណនា ហាក់ដូចបានយល់
និមលភក្ត្រា ព្រះប្អូនពំង៉ា នូវរាជបុត្រថ្ងៃ ៗ
ត្រាន់បានស្រយាល ល្ហែល្ហើយស្រាកស្រាល ព្រះរាជហឫទ័យ

ពុំសូវសោកា ក្សត្រាជៀសដៃ រួតរះពេកក្រៃ
ដល់ចុងសោមា ៗ ក្សត្រក្សាន្តនិមល បញ្ឈប់រហ៍ពល
ពួនពីងព្រឹក្សា ពុំឲ្យយក្ខយល់ កិច្ចកលក្សត្រា
ស្តែងស្តេចលីលា មុះមកដល់ថ្វាត់ ៗ ហើយព្រះកូធ
យានយាសបេរបេរ នូវកីលៀនក្សត្រ ទាំង ៤ ជិតដោយ
ពុំឲ្យប្រាស់ព្រាត់ កំដរសោះស្ងាត់ ដើរដោយមាគ៌ា ៗ
ស្តេចសោកបំភ្កាន ហើយចំយាសយាន ខ្ញាញ់ឃ្នាតក្តាត់ណា
ថ្ងៃនោះរាជបុត្រ ពិសុទ្ធស្នេហា គង់ព្រះបន្ទា
ប្រពាទលេងលង ៗ ក្អេងទាំងមួយពាន់ ត្រៀបត្រាណាសំណាន់
សើចលេងអឹងកង ខ្លះរាំខ្លះប្រៀង សូរសៀងរំពង
ខ្លះកាត់វល្លិចង់ ផ្គុំទោងយោលលេង ខ្លះបេះបានផ្កា
សិកសៀតកាមា ញញឹមអរឯង ខ្លះបេះខ្លះក្រង
ជួតចង់ឥតក្រែង គ្នាខ្លះដើរលេង បេះផលព្រឹក្សា ៗ
ខ្លះឡើងខ្លះពាន ប្រយុងបេះបាន សួរសព្វសាខា
ខ្លះឡើងដល់ចុង អង្រួនឲ្យគ្នា រករើសគោក្តា
ផ្អែតផ្អូនទីទៃ ៗ អ្នកខ្លះឈ្នះឈ្នាន ដណ្តើមចង់បាន
រួតរត់វិលវៃ ប្រពួនពានពា លើគ្នានោះនៃ
ខៀវខ្ចាក្នុងព្រៃ សឹងស័ព្ទកុមារ ៗ ឯអង្គព្រះបាទ
ដៃដេតននាថ ស្តែងស្តេចយាត្រា ទៅទៀបហើយស្តាប់

សួរសព្ទនោះណា　បើកបន្ទូលថា　នឹងកិលៀងទ្វី ៗ
បងអើយសួរសៀង　សួរសើចសួរប្រៀង　អឹងកងកលអ្វី
មនុស្សប្តួយក្បា　អាសុភអាសុរី　យល់អគ្គីក្តី
គួរយើងយាត្រា ៗ　ទៅមើលឲ្យយល់　ឲ្យដឹងកិច្ចកល
មនុស្សកាចប្តជា　បើល្មមសួរសាន　ពតិមានប្អូនក្យា
នូវរាជបុត្រា　សួរសព្ទថប់ក្រៃ ៗ　បន្ទូលតែម្ដោះ
ចរចូលចំពោះ　កុមារថ្លាថ្លៃ　ផ្ទាប់ផ្ទួងលាក់ខ្លួន
តឹងតួនប្រែប្រែ　បារម្ភក្រែងភ័យ　យក្ខយុងអាសុភ ៗ
ស្តេចលបល្អបមើល　បុត្ររតប្រែសើរ　គង់ព្រះបន្ទា
ទាំងកីលៀង ៤　វៃងស្ងួនរក្ស　នូវអស់កុមារ
បំរើរៀងភយ ៗ　ស្តេចទតយល់ច្បាស់　បើកបន្ទូលត្រាស់
ថាហៃបង្អើយ　នេះបុត្រនរណា　សោភាឆោមឆាយ
ល្អអ្វីអម្បាយ　អស់អង្គរូប៉ា ៗ　មុខឲ្យស្រឡាញ់
ទន់ក្អនល្ពៅល្ពញ　ល្អាយល្អងកាយា　ពូជពង្សអម្បូរ
ត្រកូលវង្សា　សំបុត្រក្សត្រា　មែនមិនក្បីក្បាយ ៗ
កាលនោះព្រះកី　លៀងវរន្ទ្ទ　ទូលក្សត្រពន្លាយ
បពិត្រខ្ញុំមើល　ដំណើរទ្រង់ត្រាយ　មិនមែនដៀសឆ្ងាយ
ពីព្រះរាជា ៗ　ក្រែងតែព្រះរាជ　បុត្រាឯងអាច
ចរចេញលីលា　មិនអ្នកដទៃ　ក្រៅក្រែឡើយណា

ល្មមនោះនាយា សុខសួនវិស័យ ៗ ធ្វើម្ដេចឲ្យបាន
សាកសួរពត៌មាន ឥឡូវនេះនៃ ក្រែងបុណ្យបានជួន
បុត្រស្ងួនថ្ងើមថ្ងៃ ទឹងបានអាស្រ័យ ដ្បិតបុណ្យបុត្រា ៗ
ស្ដេចស្ដាប់ទំនួល ព្រះកិលៀងទូល គ្នាន់ក្នុងចិន្ដា
ពុំអស់ព្រះទ័យ សង្ស័យក្ដាត់ណា ចំយាងយាត្រា
បរបួលទៅហោង ៗ ក្មេងច្រើនដាសដាល យល់ព្រះភូបាល
ចូលជិតជាម្ដង មន្ទិលមិនដឹង ខេចិងកន្ទង
ស្រែកដន្ទឹងកង នេះមកពីឯណា ៗ តក្រុករុកពន
ពុំគិតក្រែងមាន ទើសទាស់អាត្មា ហេតុម្ដេចចូលប្រាប់
ឆាប់ ៗ រួសរ មកមានប្រាថ្នា ប្រការគិតអ្វី ៗ
ស្ដេចស្ដាប់ក្មេងប្រឹង ស្រែកដោដន្ទឹង ក្សេនព្រះចក្រី
បៀតបានចូលជិត ធ្វើស្និតមេត្រី បើកបន្ទូលខ្មី
លួងលោមរួសរាន់ ៗ ទៅហើយនោះអ្នក ណានៃទ្រង់លក្ខណ៍
លើមណ្ឌលឋាន គោនុនាមា វង្សាសន្ដាន
ជាបុត្រក្សត្រក្សាន ប្ដីស្ដ្រីប្រជា ៗ ចូលទៅដំណាល
ដំណើរគេរគាល ពីដើមអាតីតា យើងទឹងចង់ស្គាល់
ពង្សញាតិមេបា កុំទៅមោសា វេវេចស្រដី ៗ
កាលនោះក្មេងផង ថ្លាស់ឆ្លើយអឹងកង ប្រាប់ព្រះចក្រី
ជាពជកុមារ ថ្ងៃថ្វាពិសី ជាទៅបុរី

សឹងហុនយក្សា ៗ រំព្រះជនី ប្រសើរស្រស់ស្រី
ឈ្មោះសុវណ្ណា ទ្រោយធិបេស ពិសេសស្នេហា
អយុគោស្នេហា សួនគ្រងសព្វថ្ងៃ ៗ ក្បិនក្បត្រវលក្ខណ៍
ស្តែងស្តេចស្តាប់ជាក់ អវឯងពេកក្រៃ ជៀជាពជបុត្រ
ពិសុទ្ធថ្មើមថ្ងៃ ពិតពុំសង្ស័យ ក្នុងព្រះបិត្តា ៗ ព្រះអង្គអួលអាក់
ផលនេត្រសស្រោក ព្រះទស្សថ្លែងថា កូនអើយទើបថ្ងៃ
នេះនៃបិតា បានយល់មុខបា បណ្តូលថ្មើមថ្ងៃ ៗ
ឯអស់កុមារ ត្រូព្រះភូបាល បន្ទូលហោះនៃ
រត់ទៅក្រាបទូល ឥស្សរថ្លាថ្លៃ សូមជ្រាបព្រះទ័យ
ឥឡូវនេះណា ៗ មែនមានអ្នកបើ ស្វះស្វែងត្រេបដើរ
ព្រៃព្រឹក្សអគ្គា មកសួរពត៌មាន ក្សត្រក្សាន្តថ្លៃថ្លា
សែនសោយសោកា ណាល់ណាស់សែនធ្ងួ ៗ ពោលពាក្យសៅសៅ
ថាព្រះបោមចៅ ជាបុត្រឥន្ទ្រីយ៍ បានហួសពេកពន់
លើសលន់អស់ក្តី ពុំដឹងក្រៃក្រៃ ក្រែងក្រោយឡើយណា ៗ

## បទពំនោល

ក្បិណ្ណាះពង្សពោធិវង្ស ជ្រាបហើយស្តេចទ្រង់
ព្រះក្រោធពន្លឹកមហិមា ៗ ពុំស្គាល់ជាព្រះបិតា
ថានៃនរណា បន្ទាប់បណ្តាលទោសធ្ងន់ ៗ
ឥតហេតុគួរខ្ញាស់ពេកពន់ ស្ទិក្សយ័ដីបផន្ទ

ឬថយពុំថយទៀយណា ។
ចុះចាកព្រះពន្លា
ទតយល់ព្រះបិតាថ្ងៃ
ហើយអ្នកសន្ទៀនព្រឹក្សា ។
អង្គជាបិតា
ឬយល់យើងក្មេងនេះម្ដង
រិទ្ធីនូវរិទ្ធិបេស្ដា ។
យកម៉្ដេចការុណា
ពុំស្ដាយឯជន្មជីវិត
ឥឡូវពុំលែងទៀយហោង ។
ស្ដាប់បុត្រស្ងួនគ្រឹង
ស្ដេចបើកព្រះឱស្ឋលោមថា
សំលួតសំឡាញ់ក្លាប្រើ ។
ស្ដាប់សាសំដី
កាលនោះរាជបុត្តពន្លក
ពាក្យពីព្រះវរបិតា ។
កេសសរសេក្ដីថ្វា
សូរស័ព្ទកាសុណីបីគគុក
រលុំលើងព្រឹក្សា ។

ស្ដេចទ្រង់ឆ្ពរសេចន៍ថា
សីហនាដគគាតនិភ័យ
បន្ទូលថាហៃ
ពោលពើសើវើហ៊ានថា
អញតើអញត្រើអើផង ។
បិត្តអ្នកបង់លង់
គួបពិតដួបពេជ្រផ្កាញផ្កា
មកលង់លេងលើពេជ្រពិត ។
នូវក្សយ័ល្អោបល្អិត
កាលនោះបិតាប្យះប្យង
គ្រវគ្រាធកិពេធព្ទោះណា ។
ហៃស្ងួនពុំស៊ា
កុំគាលក្រោធក្រៃសេទ្ធ
អំពើអំពីមុនមក ។
ស្ដាប់ហើយពុំយក
រិងទ្រង់ព្រះក្រោធមហិមា
ថ្វីងផ្កាញសម្ដេចព្រះជិនុក ។
ប្រិចពីទ្រុតស្វុត
ស្វាមស្ទឹកដើមជង់រុក្ខា

ត្រួលត្រួយផ្លែផ្កា រង្គំរង្គោះពេញព្រៃ ៗ
អំម្រឹកបីគគិកខ្លាំងក្រៃ ផ្អូកផ្អើលកិតកៃ
ប្រពួនប្រពានលើគ្នា ៗ កក្រើកសមុទ្រដលសា
ពុះពោមហិមា រំជុំរំជួនរំស្ងួនស្ងប់ ៗ
គេក្សាមាវេហាស៍បីត្រឡប់ អប្បអន្ធការគ្រប់
ស្រពាប់ស្រទុំមេឃមី ៗ ថ្កើងអគ្គីថ្កើងពន្យថ្កើងកើត
គេន្ទ្រប្រឹនជាស់ដេរ ពឹងពួនប្របួនគ្រប់គ្នា ៗ
យកដៃចាប់ចុកកាមា លុះលាន់មាត់ថា
ស្លាប់ហើយហ្វើម្ចឹងនេះម្ដង ៗ សព្ទនោះឮមាត់បំពង
ផល់យក្សយុងយួង ព្រះចៅសឹងហុនកាសុក ៗ
ស្ដេចស្មានជនតោពំង៉ា លង់សិលសថ្វា
ពុំដឹងសុនសាមកដល់ ៗ វីសេរសក្ដិរុទ្ធពល
ពុំអាចត្រូវផល់ សម្ដេចព្រះវរបិតា ៗ
កើតក្លាយជាពជបុប្ផា ក្រីផងនានា
ក៏ថ្វាយព្រះបាទនរុប្បតី ៗ រីពជកុមារពីសី
ពួជពង្សជាតី រិងក្រោធកិពេធមហិមា ៗ
តើសកៅទាន់ទៀតថ្វែងថា សរសោតក្លាយជា
ក្លឹងក្លស់ទូវអក្ដិរំ ៗ ធត្រធាយាតាំងជត្រសុំ
បើកប៉ាំងបរយុំ រំកើយរំកាយសោះសា ៗ

រីឯខ្វល់ទ្រង់ទៀតច្រើនគ្រា    សរសឹងក្វាយផា
អាហារត្រកាលសោតសល់ ៗ    ថ្វាយព្រះបីតាទសពល
អ្នកទតហើយធ្វល់    ដោយទ្រង់ពុំគិតសង្កា ៗ
ទើបអ្នកទ្រង់ព្រះបន្ទា    ហេតុអ្វីប្អេះណា
ក៏យល់អស្ចារ្យពេកក្រៃ ៗ    ហើយទើបដាក់ធុរសប្ប័យ
វេលាទៅញ    ប្រយោជន៍ផ្តឹងដើមក្តី ៗ

## បទកាក

ពង្សពុទ្ធកូល    យានយាសបរបូល    ក្បិនព្រះបីតា
ស្តេចទតទៅយល់    និមលពំណឹា    អរឯងប្រព
បីបាទពិនិត្យ ៗ    បរបោសបបក់    ព្រលឹងនៃអ្នក
ឧបអគ្គិរតរិត    ល្អងលោមត្រេកត្រេះ    សំណោះស្នេស្និត
ហៃមាសខ្វំមចិត្ត    សំឡាញ់បីតា ៗ    ស្ងួនឡើយឪពុក
សរស្រើនរងទុក្ខ    ព្រាត់ប្រាសពីបា    ទើបថ្ងៃនេះហើយ
គ្រាន់សៀយទុក្ខា    ជ្រិតបានយល់បា    បុត្របន្ទូលថ្វៃ ៗ
តែនៅបប់សល់    ជ្រិតពុំទាន់យល់    ម្តាយបានោះនៃ
ថប់មួយសោតណា    យកក្បាដៀសដៃ    ក្រែងទ្រង់ក្រោធក្រៃ
ពុំអត់ទោសា ៗ    រីពជឪរស    ស្តាប់ឧក្កាស្មោះ
ព្រះវរបិតា    ហេតុជ្រិតពុំស្គាល់    ពិកលក្តាត់ណា
ស្តេចពុំជឿផា    សម្តេចជីនក់ ៗ    ទើបទ្រង់បរបារ

នៃអ្នកៗថា អ្នកជាឪពុក យើងនៅពីក័ល
ពុំស្គាល់មាត់មុខ ថាតែឪពុក ឪពុកត្រង់ណា ៗ
ឪពុកនឹងកូន ពុំដែលសោះសូន្យ មិនស្គាល់មុខគ្នា
អ្នកយល់យើងក្មេង ពុំដឹងឡើយណា តាមតែនឹងថា
លលាក់លលើ ៗ ប្រសិនជ្រាបទៅ យក្ខយង់ហោមហៅ
គុណធ្ងន់ឥតស្មើ សំនឹងខ្ញាល់ណាស់ នឹងត្រាស់ឲ្យធ្វើ
ទោសតាមអំពើ មិនទេឡើយណា ៗ ស្តេចស្តាប់កុមារ
ទើបព្រះភូបាល ថ្នមថើបកក្រ្តា ហៃស្ងួនត្រកាល
ស្តាប់សាស្នេហា ឪពុកប្រាប់ប្រា ដោយដំណើរខ្ញី ៗ
កើតកាលអតីតា ព្រះឮយុគា អយ្យកោបុត្តី
ស្តេចស្ថិតទូរនា ពារាណសី ព្រះនាមចក្រី
សនុពជា ៗ រីព្រះអគ្គអគ្គ មហេសីវរលក្ខណ៍
ទ្រង់ព្រះនាម្មា នាងកេសណី ពីសីសោភា
មានរាជធិតា ប្រសើរស្រស់ស្រី ៗ នាមនាងនោះហាង
ឈ្មោះចម្ប៉ាថោង ល្អល្អះប្រិម់ប្រិ មែនមានបុណ្យ
ចំប៉ាសុវណ្ណី ជ្រុះចុះអំពី ព្រះឧស្ទជិតា ៗ
នាងនោះឯងនៃ មិនគឺជទៃ គឺព្រះមាតា
កូនស្ងួនឧត្តម បាកុំសង្កា មែនមិនមោសា
ភកូតឡើយហោង ៗ ស្តេចប្រាប់កាលគ្រា នាងនឹងកុម្ភា

ជាហេតុចំនង កាលនាងបរពាក ផ្អោះផ្អាកហោយផង
ឯគោត្តាត់ហោង នឹងនាងវិទ្យា ៗ ប្រាប់កាលកុម្ភី
ក្សិនក្សយ័ជីវី ហើយនាងយាត្រា ប្រាប់កាលនាគពជ
អំណាចសោកា ឲ្យទិសថ្វា ជួយព្រះជន្មា ៗ
ប្រាប់កាលដល់ស្រះ នោះនាងប្រទះ កុម្ភណ្ឌនោះភា
ចាប់បានក្សត្រី ពីសីសោកា ប៉ុនប៉ង់ប្រាថ្នា
យកធ្វើចំណី ៗ គេជះបុណ្យមាន សានពីបូកណា
បរមជាត្តី ក្សិនក្រុងអាសុរិន កុម្ភិទ្ធធិបតី
ស្តេចមកដល់ទ្វា ពុំឲ្យប្រហា ៗ ប្រាប់ពីយក្ខយង់
ពិសេសសឹងទ្រង់ ព្រះរាជករុណា យកជារាជបុត្រ
ពិសុទ្ធស្នេហា ឲ្យគង់លើប្រា សាទស្ពូតិមង្គល ៗ
ហើយព្រះកុម្ភី ប្រាប់ព្រះជំនី ជំនក់ទសពល
ប្រាប់ពីស្តេចស្តែង វាង្វេងដើរដល់ ស្រះស្រង់យង់យល់
កុម្ភណ្ឌយក្សា ៗ កាលយក្ខខឹងខំ ទ្រទ្រុស្នាដេញជំ
លុះឡើងលើប្រា សាទសោតពុំស្គាល់ កិតញ្ញូរអង្គា
នាងនាដមេត្តា រស់រួចជីវី ៗ ប្រាប់កាលព្រះបាទ
សឹងហុនននាដ ផ្សងទឹងក្សត្រី កាលពីព្រះអង្គ
ពុំលង់ស្តេចទ្វា បំរើនព្រះស្រី បុត្រពីរអង្គា ៗ
ប្រាប់កាលស្តេចបាន នាងវិលមកឋាន ហោមន្តភាព

ប្រាប់កាលព្រះចៅ ស្តេចទៅព្រឹក្សា តាមទាក់គុជ្ឈា
សសុទ្ធនោះនៃ ៗ ប្រាប់កាលនាងនាជ ប្រាប់ពីរកំណាច
ចិត្តចោរចង្រៃ កាលនាងសម្រាល កុមារស្ទើមថ្ងៃ
ធ្លាក់ឈើវិសេ ទុកតាងបុត្រា ៗ យកកូនទៅកប់
នៅនាក្រោមម្លប់ ព្រះដៃសាខា ប្រាប់កាលក្សត្រក្សាន្ត
វិលថ្កានសេមា ទ្រង់ព្រះក្រោធា បណ្តាញក្សត្រ ៗ
ប្រាប់ពីព្រះអង្គ តាមនាងលុះលុង ចូលជាឆ្នាំបី
ទើបថ្ងៃនេះបាន ដឹងជានសេចក្តី ពីមាសពីសី
បណ្តូលស្នេហា ៗ កូនឡើយឪពុក ថ្វោះត្លាយចោតផុក
ដោយតែពាក្យវ៉ កាប់កិនញុសញុង បរបង់ឃ្វាតឃ្វា
សំក្រុងគាសុក ខ្វាល់គ្រែគន្ទុក ៗ តាំងចេរតែបា
ប្រែណីបីតា ជួយដោះសាសង
ទោសតាំងនេះគួន់ ពោកពានកន្ទុង ប្រាជួយចូរផង
អង្វរយកក្សា ៗ កាលនោះព្រះពោ ជិសត្តសេរថ្វា
ស្ដាប់ព្រះបីតា ហើយយល់ជាក់ស្បាន់ សុវណ្ណបំប៉
ជឿជាបីតា ពិតពុំសង្ស ៗ អ្នកឪនអង្គា
ថ្វាយវរន្ទា លុះលើសិរថ្ងៃ ទ្រង់ព្រះកន្សែង
ហូរល្ហុងនេត្រនៃ គិហោបលុងក្រៃ កាណាតបីតា ៗ
ទ្រុងទ្រួតស្មើបែក រិះរិងសង្វេត ធុរេទុក្ខា

បាបស្ដេចឲ្យឃ្លាត ព្រះញាតិវង្សា គេហៅចកំព្រា
ដល់ជម្ងន់អាយ ៗ ហើយពុំទូលគួល ប្រណម្យក្រាបទូល
បីតាព្រនាយ កុំជាទុក្ខធំ ជាខ្ញុំគិតថ្វាយ
ទីនទូលដោះស្រាយ ទោសទាំងនេះណា ៗ កាលនោះព្រះបាទ
ដៃដេតនទាថ ស្ដាប់បុត្តពំនា បម្លោស្រកស្រាល
ស្រយាលសោកា កាលនោះសុរិយា រសៀលទាបទន់ ៗ
ព្រះពោធិសត្វ ស្ដេចទឹងវិលថ្វាត់ មន្ទីទព្វតន់
អញ្ជើញបីតា ថៃថ្វាលើសលន់ ស្ដេចមកដល់មុខ
ទល់ទីមាត់ទ្វារ ៗ ព្រះពន់ពុំទូស្យ ពន្ទុកប្បងប្បះ
លើសលែងលោកា ឲ្យព្រះវរបី គង់ព្ធមាត់ទ្វារ
ឲ្យអស់ក្នាក់ផា បំពេរក្រ ៗ ហើយយកទឹកអប់
ពិដោត្រឡប់ ស្រង់ព្រះភជា ក្រលេះបួងចាន់
សុគន្ធមាលា ថ្វាយព្រះបីតា លះយលាបព្រះអង្គ ៗ
មានទាំងអាហារ គ្រាកាលពិសា គ្រឿងគ្រប់សឹងផ្ទង់
ស្រេចហើយកុមារ ពិសាលវរវង្ស ពិតពុំផ្សព្វផ្សង
ឡើយស្ដេចលីល្ហា ៗ ថ្កានព្រះដំនី ប្រសើរស្រស់ស្រី
កែវសុវណ្ណា នាងនាថយុងយល់ បុត្តដល់ហើយណា
អរទបប្រាំ ថ្នាក់ថ្នមក្យាប្រិ ៗ ថៃថើបព្រះភក្ត្រ
ល្អងលោមថាអ្នក មាសមិត្តពីសី ថៃនេះយូរគ្ដាត់

លុះដល់រាត្រី　ប្រការកលអ្វី　មិនជួបសព្វគ្រា ៗ
ឯពន្យព្រុទ្ធស　ស្តាប់ព្រះមេត្រាស់　ដន្ទឹងបោះណា
ទឹងទូលដោយត្រង់　ខ្លាចព្រះទេយ្យា　ព្រះវរមាតា
ខ្វាល់ទឹងបក្រី ៗ　ទ្រង់គិតហើយថ្វាយ　បង្គកាយ
លុះលើសិរសី　ទើបទូលអំភ្វាន　វៃវាងសេចក្តី
ប្រាយប្រាប់ដំទី　ពិតពុំឲ្យគ្គង ៗ　សូមទានទំទៅ
លេងលុះព្រៃជ្រៅ　ឆ្ងាយក្រៃកន្ទង　វិលមកក្រដល់
ដូចកាលសព្វដង　ត្រឡប់ហើយហោង　ទើបផល់នេះណា ៗ
ឯព្រះជំនី　ស្តាប់សាសំដី　ស្មានស្មោះដូចថា
ពុំដឹងស្តេចដល់　មណ្ឌលទៀយណា　ចរបូលទិន្ទ្រា
សៀមស្ងាត់ប្រែគុំ ៗ　នាងនាថក្រញូក្រង　បុត្រថ្លៃវរវង្ស
ប្រានប្រុសឧត្តម　ក្រោមស្វេត្រឆត្រ　រួតរត់កុំរុំ
លុងតិចនាងផ្តុំ　លុនលក់ហើយណា ៗ　អគ្រាតស្រងាត់
មហាបុរសគេ　ពុំស្គាល់ទិន្ទ្រា　ក្បែកក្បួលអួលអាក់
សស្រាក់សោកា　រលឹកបីតា　លុះល្ហាប់ហាប្ញទ័យ ៗ
ក្បែនព្រះមាតា　តើនបាកទិន្ទ្រា　យល់ពជបុត្រថ្លៃ
សោយសោកនោះនាង　លោមក្វាងថាហៃ　កូនកែវប្រែពៃ
សំខ្សាញ់ពាំភា ៗ　ស្ងន្ទើយហោតុអ្វី　យល់អព្ភ័ក្តី
ទឹងអស់សព្វគ្រា　មាសថ្លៃឧត្តម　ប៉ាយុំតើប៉ា

ឆ្គងចិត្តត្រង់ណា　មិនបានជួបប័ន ៗ　ប្ដូមួយមេទុំ
សៅដៃព្រះស្នំ　មុខមន្ត្រីផង　ប្ដូព្រះញយុគោ
សេហោបៀះបៀន　ប្ដូមួយបាគ្គង　ចិត្តទឹងម្ដាយបា ៗ
ទ្រព្យអ្វីត្រកាល　កុំឈង់កពកា　ទាស់ចិត្តចិន្តា
កូនកៅតែមួយ　ជាទ្រួយទេយ្យា　ប្រាយប្រាប់ម្ដាយភា
សោះម្ដាយថប់ក្រៃ ៗ　ព្រះពោធិសត្ត　ប្រណម្យទូលភ្ញាត់
សាសង់សុមៃ　ខ្ញុំពុំមានអាក់　ថ្នាំងថ្នាក់ព្រះទ័យ
ទឹងអ្នកណានៃ　អគ្គីហ្នោះណា ៗ　អម្ចាស់ខ្ញុំមើយ
ខ្ញុំលាក់អ្វីឡើយ　ខ្ញុំថប់មហិមា　ទឹងព្រះជិនក់
ទល់ទុក្ខកំព្រា　ឥឡូវស្ដេចយា　ត្រាត្រេបមកដល់ ៗ
ស្ដេចមកពីនាយ　ទម្រាំដល់អាយ　បីឆ្នាំសោតសរប់
ព្រួយព្រះអគ្គឯង　វង្វេងវិលវល់　ផ្លូវឆ្ងាពុំយល់
ភនរុកព្រឹក្សា ៗ　ស្រាប់តែចូលដល់　នូវនាមណ្ឌល
ទីព្រះពន្លា　ទើបស្ដេចសាកសួរ　ដួរបួរមេបា
ហើយថាបិតា　បង្កើតខ្ញុំហោង ៗ　ខ្ញុំខឹងពេកក្រៃ
ផ្កាផ្លែងសរផៃ　ប្រឹនត្រាប្រឹនផង　ពុំបានត្រូវត្រង់
ព្រះអគ្គបៀះបៀង　ខ្ញុំដាក់ធ្នូគង　ចូលទៅម្នីម្នា ៗ
ព្រះអគ្គីរៀបពប់　ដំណើរប្រាយប្រាប់　ពីមុនមកណា
កាលព្រះអយកោ　សេហោថ្ងៃថ្ងា　ដឹកបលុះត្រា

ឥឡូវនេះហោង ថាទ្រង់នៅនា ហេមន្តភាព
ជាទុក្ខមួរម៉ង តែងតែសោកសៅ ក្តាត់ក្តៅកន្ទួង
នឹកមាតាផង នឹងបុត្រាថ្លៃ ។ នឹងទៅឃូរលង់
សំអ្នកនឹងទ្រង់ កន្ទ្រែងលុះក្រែ ជាវេភកម្ម
បងចាំពៀក័យ ជិតដោយអគ្គអែ មិនមានឃ្លាតឃ្លា ៗ
ទាំងនេះហេតុតែ បាបពីបុព្វ និរាសនាយណា
ឲ្យយើងតោកយ៉ាក លំបាកមហិមា នេះហៅទុក្ខា
អនត្តាអទិព្វ ៗ គួរគិតវេក ទោះទេពទេវ
សួគិសោឡស្រាំង ពុំដែលជៀសចាក ផ្ទោះផ្ទាកកំបាំង
ជ្សិតបាបមានតាំង និតនូវក្នុងកាយ ៗ ទោះទោសប៉ុន្មាន
សូមអ្នកកំសាន ព្រះទ័យសប្បាយ ភាសូវខ្ញុំជា
បុត្រាឆោមឆាយ កំព្រានូវអាយ ឥតញាតិវង្ស ៗ
កាឈ្មោះនាងនាថ ស្តាប់ធុរសរត ទូលដូរឈ្មោះណា
ត្រឹព្រះហឫទ័យ អរក្រៃមហិមា ស្រានស្រាកទុក្ខា
ស្រយាលល្ហែល្ហើយ ៗ ទើបនាងត្រាស់ថា ហៃកូនពំរ៉ា
សម្ងាញ់ម្តាយអើយ ពីដួចម្តាយឃ្លាត ព្រះបាទត្រានត្រើយ
ទុក្ខម្តាយពុំស្បើយ សព្វទិនទិវា ៗ ថ្ងៃនេះទើបបាន
ដឹងដោយពាតមាន ពីកូនកំព្រា ម្តាយពុំតបស្នង
នូវបងចិត្តជា . ទោសទេកុំបា បារម្ភឡើយហោង ៗ

សព្វថ្ងៃម្ដាយគិត អួលអន់អាណិត ព្រះបាទព្រះបង
ទាស់តែជាស្រី ក្រក្រីកទូង ស្រដីក្រែងខ្គង
នឹងព្រះបីតា ៗ បើមាសបណ្ដូល មេត្តាអាសូរ
ព្រះជិនុកបា ចូលទូលអាសុរិន កូម៉ិនថ្ងៃថ្ងា
ស្ដេចព្រមមេត្តា ម្ដាយនឹងថាអ្វី ៗ សព្វថ្ងៃយើងនៅ
នេះនឹងព្រះចៅ បក្រវត្ដធិបតី នឹងគិតតាក់តែង
អង្គឯងជាស្រី ខុសច្បាប់អំពី បុពណានោះណា ៗ
ឯពង្សត្រុទ្ធរត ស្ដែងស្ដាប់សាស័ព្ទ ព្រះវរមាតា
អ្នកថ្វាយបង្គំ ប្រណម្យទូលថា ឈ្មោះខ្ញុំឆានា
ទូលក្រុងអាសុរី ៗ ហើយព្រះអង្គលា ព្រះវរមាតា
ស្ដែងស្ដេចទៅខ្ចី ដល់ព្រះព្យុកោ សេថោធិបតី
ទូនអង្គសិរសី ក្រាបបាទយក្សា ៗ យក្ខយល់ជនគោ
រុសពយត្រេកអរ សោមនស្សប្រែប ឱបអង្គឱរស
ស្ទាក់ស្ទោះស្នេហា លួងលោមបរប៉ារ ថើបថៃផ្ដកផ្ដិត ៗ
ថ្នាក់ថ្នមត្រកង មិនឲ្យមានហ្មង កកៀករួតរិត
មិនឲ្យអាក់អន់ ស្រពន់ក្នុងចិត្ត ស្រឡាញ់ស្នេស្និត
រួមឯកជីវិ ៗ កាល្នោះព្រះអង្គ អម្បូរពូជពង្ស
ពទ្ធកជិនស្រី អ្នកនឹងបានត្រាស់ ច្បងច្បះជាអី
សួរសត្វកពាត្រែ ប្រាកដក្ដាត់ហោង ៗ អ្នកឱនអក្ដី

វាទវាទី ក្រោយក្មួយន៍យួន ទើបទូលអំពី
ព្រះបីតាហាន បុត្រនេះម្តង សូមទ្រង់ករុណា ៗ
ផ្សិតព្រះជិនុក ក្តាំធ្ងន់ធ្វើទុក្ខ ឱ្យព្រួយចិន្តា
ឲ្យភាប់ព្រះយស ផ្កាកផ្ទះឲ្យភា ស្រវពុំសត្តិយា
សាស័ប្ដវាទី ៗ ទោសនោះយល់គ្គង ឥឡូវនេះម្ដង
សូមស្ដេចប្រណី សម្លាប់ទល់ស្លាប់ ថ្វាយជនជីវី
ពុំបេរបក្រី ទ្រង់ព្រះមេត្តា ៗ ការល្មោះអយុកោ
ស្ដាប់ព្រះជនតោ សូមលាទោសរ្ង ព្រះឱស្ឋប្រែប
ញញឹមឆ្លើយថា សូន្ធើយម្ដេចបា បានស្ដាប់ជិនុក ៗ
ម្ដាយបាប្រាប់ថា អស់អាចិវាចា កិច្ចកម្មញឹកញុក
ប្ដូមួយយោធា សេនាមាត្យមុខ មន្ត្រីពីស្រុក
នាយនោះមកដល់ ៗ ឯពុទ្ធំកូល ប្រណម្យក្រាបទូល
អាសុរិនចោមពល សូមពានខ្ញុំជឹន ដំណឹងកិច្ចកល
ខ្ញុំបានយន់យល់ ព្រះវរបីតា ៗ កាលខ្ញុំចេញទៅ
ប្រពាតឋានក្រៅ បានជួបជួនគ្នា សំណោះស្រាក់ស្រួល
ទទួលបរវា ប្រាប់ពីអតីតា ដោយដំណើរនោះ ៗ
ខ្ញុំស្រាប់តែភ្ញាក់ ដឹងដោយពាក្យអ្នក ប្រាយប្រាប់ចំពោះ
ពាក្យពេចន៍កិច្ចកាម សាច់ឈាមប្លេះប្លោះ ភក្តិសូន្យសោះ
ពុំស្គាល់ឡើយណា ៗ ក្បិនក្បត្រៃយក្សយន់ ស្ដាប់ពោធិវង្ស

លេខក្បួន :
លេខបញ្ជី :

ទូលទើបត្រាស់ថា ចូលបុរាអង្វរ ព្រះវរមាតា
នាងព្រមហើយណា តាមចិត្តនាងហោង ៗ ទើបពុំទូល
ប្យះប្យងក្រាបទូល ទូលតបទៀតស្ងួន រ៉ព្រះមាតា
ណ៎ នាខ្ញុំហោង ក្រាបទូលរាប់រង កុំព្រួយទេយ៉ា ៗ
ស្ដេចស្ដាប់ដនតា ទើបព្រះអយុកោ បន្ទូលត្រាស់ថា
បើឈ្មោះជិនុក ឪពុកនៃបា តើនៅឯណា
ឲ្យហៅមកហោង ៗ ក្បិនព្រះភូមី ស្ដេចត្រាស់ប្រើគី
លៀន ៤ បវត្ដន អញ្ជើញក្សត្រា បីតាប្យះប្យង
ដល់ដូចបំណង ថ្វាត់ថ្វាយវន្ទា ៗ ទូលថាសូមទាន
រាជបុត្តកល្យាណ ប្រើខ្ញុំករុណា អញ្ជើញព្រះបាទ
ននាថថ្ងៃថ្វា ឲ្យស្ដេចយាត្រា បង្គំយក្សយុង ៗ
ស្ដេចស្ដាប់ទទួល ក្សត្រថ្លៃត្រកូល មីមាពុំលង់
ប្រដាប់គាត្នា ក្សត្រាវរវង្ស លីលាដល់ចុង
ភេទវតវច្ចទា ៗ ស្ដេចគង់ស្ដេចថ្វាយ បង្គិកកាយ
ក្រញូក្រាបសិរសា ព្រញ្ញប្រាទពុំឈប ដោយខ្លាចបេស្ដា
កាលនោះយកក្រ ស្ដេចទតទៅយល់ ៗ បន្ទូលចំពោះ
តម្រង់ទៅស្មោះ ដៃដេតទសពល ថាហៃព្រះស្ដេង
ពុំធ្វេងកាកល ឥឡូវមកដល់ បង្គំយើងថ្វី ៗ
យើងដែលឯណា មានកូនប្រុសា ដូចទៅឬអ្វី

អំពើពុំគោត ធុកធោតអស់ក្ដី យកតែពាក្យស្រី
ប្រាំពីរនោះណា ៗ ពុំហាំសំដី ចោមចៅចក្រី
លោកដែលមោសា វៀចវេឃ្វាតឃ្វៀង ពុំទៀងសត្តិយា
បំពោតយើងជា ឥតុកពុំក្រែង ៗ ទោះយើងថ្កែធ្លា
ពុំស្មើពង្សា គួរគិតគួរឈ្លង វិសេសដោយច្បាប់
ជម្រាប់ពីព្រេង ឲ្យយល់ជាក់ស្ដែង ស្ដាប់ដោយភិធា ៗ
នេះមួងបំបេរ ឲ្យនាងចេញចេរ ឯកអង្គគាថា
ដងព្រៃទូរគំ ប្រឹងសោះសា ល្អុកបើដេយ្យា
មមែនហើយតើ ៗ ចោះនឹងយាត្រា គាមរកអ្នកណា
ដោយចិត្តអំពើ សំនឹងឥតការ អាសាឥតបើ
វិសេសកលធ្វើ មេចយល់កត្ដា ៗ ប្រាប់ហើយមួយមាត់
ឲ្យជឹងសាសព្វ ទោះគាបទោះជា មេចឡើយក្រែវក្រោធ
កំពេធសោះសោ ពុំពីចារណា ឲ្យយល់ខុសគាប់ ៗ
គិតហើយគួរខ្លាស មុខមន្ត្រីព្រស្ដ្រ អស់អញសូវស្លាប់
បើចិត្តជលមួង ក្រោកឡើងកុំក្រោប ប្រែងប្រានប្រដាប់
សង្គ្រាមទឹងគ្នា ៗ តែគួរតគួរ បើយើងមិនសូរ
ថោកថយវិទ្ធា ស្ដាប់កំពេញប្រុស នឹងរស់ប៉ុជា
ជំនៀលនិន្ទា មនុស្សលោកទាំងឡាយ ៗ កាលនោះព្រះបាទ
ដៃដេតនទាថ ស្ដាប់យក្ខពន្រាយ ស្ដេចរង្គិតខ្ចាប

គ្រួញក្រាបម៉បម៉ាយ ពុំអាចបែងចាយ ទូលតបឡើយណា ។
កាលនោះព្រះអង្គ ត្រកូលពូជពង្ស ពន្ទកសាស្ដា
អ្នកលើកទសករ អង្វរវន្ទា ទូលទៅសាសុក
ពាក្យពិតពុំផ្គង់ ។ បពិតព្រះអង្គ ពិសេសសូមទ្រង់
ករុណានេះម្ដង ទោសទាំងនេះធ្ងន់ ពេកពន់កន្ទង
សូមទានកុំបង ព្រះទ័យក្រោធា ។ អាសូរឯខ្ញុំ
ប្រសិនបើចំ បែងបង់បីតា អន្ទង់អន្ទោច
ត្រមោចកំព្រា សំសោយសោកា លុះលង់ជីវី
មួយត្រង់តតាំង ប្រគួតប្រណាំង ជន្ទើមរិទ្ធី
ហ៊ានម្ដេចគេជះ តបៈបារមី គុណលើសិរសី ជាខ្ញុំបាទ ។
ក្បៀនក្បែរយក្សយន់ ស្ដេចស្ដាប់ព្រះពង្ស ពន្ទកសាស្ដា
ក្បែរថ្ងៃពន្រោយ រសាយក្រោធា អាសូរកុមារ
នូវនាងនាថនៃ ។ មានព្រះបន្ទូល មធុរៈសម្រួល
ត្រាស់ប្រើសៅដៃ ចូលហៅម៉ឺនមា យាត្រាវៃ ៗ
អញ្ជើញក្សត្រ កែវសុវណ្ណា ។ កាលនោះទាសី
បង្គិបក្រិ រួសរាន់ម៉ឺនមា រួតរត់ទៅដល់
យង់យល់ធិតា ប្រណម្យទូលថា ព្រះជិនុកកូធរ ។
ឲ្យខ្ញុំនេះណា អញ្ជើញជាយា យាសយានបេរបរ
ទៅកាន់បីតា ថ្ងៃថ្វាបវរ ផ្សិតព្រះកូធរ

ព្រះពមភជា ៗ ស្តេចតាមមកដល់ ពេនវគមណ្ឌល
បត្តិបីតា អញ្ជើញស្តេចឆាប់ ប្រញាប់ម៉្មា
ព្រះវរបីតា ស្តេចទន្ទឹងក្តាត់ ៗ នាងស្តាប់សំដី
នៃមេតាសី ទូលទើបស្រីរត ប្រដាប់អាត្មា
លេលាទៀនថ្វាត់ ថ្វាយបង្គំក្សត្រ យក្ខយន់បីតា
នាងយល់ព្រះមាស អៀនទិនឯងខ្មាស់ សញ្ចុបក្រ្ដា
ពុំហ៊ានរត្ដោះត្រង់ ខ្ញាចក្រុងយក្ស លបឈ្ងៀងនេត្រា
លួចមើលម្តង ៗ ឯអគ្គព្រះបាទ ទតយល់នាងនាថ
ដល់ជួបបំណង ក្រឡេកមៀងមើល ផ្អកផ្អើលស្នេស្នង
ត្រីព្រួចគួបបង មេត្រីស្នេហា ៗ គិតថាទុមាស
ម្តេចមកប្រែប្រាស់ បង់បងឃ្លាតឃ្លា អម្ងន់លន់សល់
ទើបយល់តក្រា កណ្តាលក្រឡា ពេនវគសួស្តី ៗ
ទាស់តែខ្ញាចសក្តិ ក្សត្រកក្ខនវលក្ខ ថោមថៅអាសុរី
អគ្គីស្នុះទៅ • ជុមពៅពិសី វិតក្រួតអគ្គស្រី
ជួបជិតទុក៏ ៗ សួនទើយបងស្នេង បោះបង់លះលែង
បុរជ្ជា ពុំគិតជន្មជាតិ សង្វាតយាត្រា
យូរលង់ក្តាត់ណា បីឆ្នាំហើយហោង ៗ ទើបថ្ងៃនេះយល់
មុខមាសទិមល ហេតុតែក័ពបង ម៉េះរៀមទឹងផ្ញើ
ខ្ទនលើបុនហោង ទោះទោសបងធ្ងង តាមមេករុណា ៗ

កាលនោះពុំលង់ ក្បិនក្បែរយក្ខយង់ យល់ភដផិតា
ស្ដេចបើកព្រះស្នូរ បន្ទូលត្រាស់ថា កូនកែវពុំងា
សម្លាញ់ឪពុក ៗ ឥឡូវប្ដីនាង យាត្រាយាសយាន
មុះមកពីស្រុក ហោះបង់មន្ទីរ ជំនីជំនក់
សង្រែងវង់ទុក្ខ តាមពៅពុំងា ៗ ទេះម្ដង់បានយល់
លុះលើមណ្ឌល ពេនវត្ថុនេះណា នាងនឹងគេស្រមក្សត្ត
មុះមានមផុគា ប្ដូរម្ដេចពុំងា សូនឪពុកកើយ ៗ
ឪពុកបង់ស្លាប់ ប្ដូរមេមាសប្រាប់ កុំបែរលង់ឡើយ
ទោះពុំមូលចិត្ត ស្នេសិទ្ធិតូនើយ ថាឲ្យអស់ហើយ
តាមចិត្តកូនណា ៗ នាងស្ដាប់ព្រះវិរ បិតាកូនរ
នាងឧនសិរសា ថ្វាត់ថ្វាយបង្គំ ប្រណម្យទូលថា
សូមទានករុណា ប្រោសប្រាណមេត្រី ៗ សព្វថ្ងៃផាខ្ញុំ
ព្រះបាទបរម ននាងជំបតី ទោះអាក្រក់ល្អ
ទោះក្រភ័យក្ដី ពុំបែរចក្រែ ទ្រង់ព្រះករុណា ៗ
ទោះក្បែរវិលក្ខណ៍ ទឹងដាំទឹងដាក់ ខុសគាប់គាបផា
ខ្ញុំម្ដេចក៏ទឹង ទទឹងកាផា ពុំក្រែងអគផា
ជំនុកនោះនៃ ៗ យល់ខ្ញុំថ្វោះខ្វាយ ចបេសពុំដោយ
ក្រមក្រិត្យក្សត្រថ្ងៃ កើតកើត្តិទិន្នា អង្គភាស្រូវក្រៃ
ក្រលែងវិសេស បុរាណនាយណា ៗ មែនពិតស្វាមី

ក្រោកក្រិត្យចក្រ ធ្គន់ព្រះបិត្តា កាចកេ្ត៍គួរខ្លាស
អស់ពស្ត្រប្រជា ពុំបេរក្សត្រា ឈ្មន់សព្វសេចក្តី ។
ក្សិនក្សត្រយក្សា ស្តាប់សុវណ្ណា ទើបក្រុងអាសុរី
ព្រះឪស្តសាសន៍ ឆ្លើយធ្លន់បុត្រ ហៃមាសពីសី
ស្មើថ្មើមបីតា ។ កូន្មើយពិពេះ រីទោសទាំងនោះ
មែនហោងដូចថា ឥឡូវពុំអាច ទឹងខ្លាចបេស្តា
ចូលមកវន្ទា សូមលាទោសផង ។ អាសូរកុមារ
ជនតោត្រកាល ត្រកូលច្បះច្បង អាឡៃបីតា
មហិមាកន្ទង ចំណោទៅរង់ ទុក្ខខ្ញួញខ្លោចផ្សា ។
បើទឹងបម្រាត់ ផ្តួចសង្សាសត្វ អាចឲ្យឃ្លាតឃ្លា
បង់បាត់ឯអង្គ នោះទឹងវេទនា ទុក្ខសោកមិនត្រា
ទឹងស្បើយល្ហើយល្ហែ ។ ឥឡូវទឹងធ្យំ ផ្សាមាសឧត្តម
មូលមិត្តស្និតស្នែ នាងទឹងស្រោកស្រួស ទទួលបុ្គេ
គិតម្តេចមាសមេ ប្រាយប្រាប់មកហោង ។ នាងសុវណ្ណា
ថ្វាត់ថ្វាយវន្ទា ប្រណម្យទូលស្នង តាមព្រះករុណា
មេត្តានេះម្តង ពុំហ៊ានរំលង ពីព្រះអាជ្ញា ។
ស្តេចស្តាប់សំដី នាងសុវណ្ណី បុត្រស្ងួនសង្សា
ក្សិនក្សត្រយក្ខយុង បើកបន្ទូលថា ហៃដៃដេតបា
ស្តាប់អញនេះម្តង ។ ទោះទោសខុសខាន ឥឡូវយើងមាន

ភាសូរហើយហោង ដែហាក់យើងនៅ ឆោតខ្លៅកន្ទង
មនុស្សទេវតាផង លោកនឹងនិន្ទា ៗ បើទៅចង់ស្និត
ស្នេហាមូលមិត ដូចមុននោះណា
ទៅឡើងប្រាសាទ ស្អាងស្អាតសោភា បានហើយនឹងថា
អ្វីឡើយនេះម្តង ៗ ដៃដេតកពជា ស្តាប់ព្រះបីតា
បន្ទូលឆ្មោះហោង ស្តេចរឹងក្រញូក្រាប ស្រពាប់ពបវង
ពុំហ៊ានទូលស្នង សៀមស្ងាត់ពជា ៗ ឯអង្គក្សត្រី
ប្រសើរស្រស់ស្រី នាងសុវណ្ណា នាងថ្វាយបង្គំ
ម្រណាម្យលុតលា ព្រះវរបីតា វិលទៅវិញផ្គង ៗ
កាលនោះយក្ខយង់ ស្តេចត្រាស់ឲ្យសង់ ព្រះពន្លាហោង
ថ្វាយព្រះសុណិស្សា ថ្លៃថ្លាឥតហ្មង ពុំឲ្យគង់ផង
សម្តេចបុត្រី ៗ ដៃដេតកពជា គង់ព្រះពន្លា
នូវគស់សេណី នាងសុវណ្ណា សោភាប្រិមប្រិ
រៀបកសពិសី ពិសេសពិសា ៗ ស្រីស្រស់ឆោមឆាយ
ឲ្យនាំមកថ្វាយ ព្រះរៀមពជា
ពុំមានឲ្យខ្វះ កន្ទុះឡើយណា សព្វទិនទេព
ពុំដាច់ឡើយហោង ៗ នាងមានប្រណី អង្គព្រះស្វាមី
ព្រះបាទព្រះបង ទាស់តែខ្វាចស័ក្តិ ក្សត្រយក្ខយង់ឃ្នង
នាងសោកទាំងវង់ ទុក្ខទៅពជា ៗ ទព្រះពន្ទុក

ស្តេចសង្វាតមក់ តាមខ្ញុំប្អូនភ្ងា លំបាកព្រះអង្គ
យូរលង់ក្តាត់ណា ស្មើក្បែរផន្ទា វង្វេងទូរទី ៗ
ឥឡូវនេះបាន ដល់ហើយមកបាន ទុក្ខទៀតច្រើនក្តី
ខ្ញុំគិតផ្ដេផ្ដា ខ្ញុំមហាប្រណី ព្រះបាទចក្រី
អម្ចាស់សិរសា ៗ តេងតាងគំនិត ក្រៃក្រនឹងគិត
ឥតបើនឹងថា រីឯពុងពោះ ល្អោបល្អុះខ្ចាបផ្កា
ហាក់ហៀបមរនា ជន្មជាតិជក ៗ ព្រះមាសឧត្តម
ស្ងះស្ងួនតាមខ្ញុំ ខ្ញុំអរមហិមា ហេតុមានព្រះទ័យ
អាឡៃខ្ញុំជា ខ្ញុំព្រះបាទា ទើបស្តេចមកហោង ៗ
ព្រះម្ចាស់ប្អូនអើយ ប្អូនគិតទៅហើយ ថៃថប់កន្ទួង
ករទ្ងង់ខ្ចាបផ្កា ទុកទឹងរង ហេតុកម្មព្រះបង
ទឹងខ្ញុំនេះណា ៗ ប្អូនទឹងអង្វរ សម្តេចក្បួរ
ជាព្រះបិតា ពុំគួរពេកពន់ ផ្ចិតផ្ចង់ចិន្តា
ឥតមាននរណា ទឹងជួយគិតផង ៗ ពីដូចប្អូនប្រាស់
ព្រាត់ព្រលឹងមាស ឆ្នាំបីហើយហោង ចិត្តប្អូនគ្មានល្ហែ
នំនេប៉ុនល្អង ទទួងព្រះបង ផ្សិតបាត់លង់លង់ ៗ
ឯអង្គព្រះបាទ ដៃដេតននាដ ស្តេចតែងនៅគង់
កងពន្ទាដៃ ក្សត្រថ្ងៃគិតគន់ នាងនាថប្អូនគន់
ពុំក្ងួបឡើយណា ៗ ហើយស្តេចតែងទៅ គាល់ព្រះពាមពៅ

អាសុរិនពជា　ប្រក្រតីពុំដាច់　សត្វចិនទេក់
លមកព្រះពន្ធា　អួលអន់ព្រះទ័យ ។　ទ្រង់ព្រះកន្សែង
លាបថ្ងឹនថ្ងៃ　ក្បឹកក្បួលពេកក្រៃ　ពិតពុំមានស្បើយ
ល្ហែល្ហើយព្រះទ័យ　មមាមមៃ　ឈឺធៀបខ្លោចផ្សា ។

## បទព្រហ្មគីត

ឱអួនស្ងួនត្រកាល　សាច់សង្ហារពីមុនព
មាសបងនេះនៅជា　ទុក្ខទូទៅពន់ប្រមាណ ។
ក្តៅក្តាត់អស់ឥន្ទ្រីយ៍　ដូចអគ្គីឆួលឆេះប្រាណ
ធ្វើម្តេចឡើយបងបាន　មាសមូលមកនឹងរៀមព ។
ប្រសិនយូរពុំបាន　មាសកល្យាណដូចប្រាថ្នា
សំបងក្ស័យជន្មា　ពិតពុំរស់រួចនេះម្តង ។
ទោះបីបងក្ស័យមែន　បងមិនឃ្លាតខ្លួនឡើយហោង
លែងតែបានស្នែស្នង　រួមមណ្ឌលមូលនឹងគ្នា ។
កាលនោះពោធិសត្វ　បុរសេតកជបុត្រា
អ្នកយល់ព្រះបិតា　ទល់ទុក្ខធ្ងន់ពន់ប្រមាណ ។
អ្នកទូលលួងលោបថា　សូមករុណាទ្រង់ព្រះក្សាន
ល្ហែល្ហើយស្រាលស្រាកស្រាន　បន្ទោរបង់លែងសោកា ។
កុំបីក្សត្រឧត្តម　ថប់បារម្ភកង់ទេយ្យា
ជាខ្ញុំនឹងធានា　ទូលអង្វរក្សត្រយក្ខុយង់ ។

លែងអ៊ីទឹងប្រោសប្រាន　　ក្សត្រប្រពានតាំងពីរពង្ស
ឲ្យមូលមួយគួរគង់　　ដូចដែលដើមមុននោះណា ៗ
ឯអគ្គព្រះភូបាល　　យល់កុមារថ្ងៃសោភា
ព្រួបព្រីព្រះទេយ្យា　　ត្រាស់សំណោះទឹងពោធី ៗ
កូន្មើយចូលបាទៅ　　ទូលព្រះចៅក្រុងអាសុរី
សូមស្ដេចមានប្រណី　　ឲ្យឪពុកស្រាលទុក្ខា ៗ
ព្រះពោធិឥសូរ　　ស្ដាប់បន្ទូលព្រះបីតា
អ្នកថ្វាយបង្គំលា　　ចរទៅឋានព្រះឮយុកោ ៗ
អ្នកក្រាមក្រោមព្រះបាទ　　អភិវាទវរវន្ទោ
ឱនអស់អង្គសិរោ　　ថ្វាយបង្គំប្រណាម្យនៅ ៗ
ឯអង្គព្រះអយុកោ　　យល់ជនតោថ្ងៃឥតសៅ
ស្ដេចថ្នមដាក់លើភ្លៅ　　ប្រោសអង្អែលព្រះអង្គា ៗ
ទើបព្រះពង្សពុទ្ធស្ស　　អ្នកទឹងត្រាស់ឮអានា
គតកាលគឹសម្មា　　សម្ពុទ្ធោជាជិនស្រី ៗ
អ្នកលើកតាំងទសករ　　ទូលអង្វរក្រុងអាសុរី
សូមទានទ្រង់ប្រណី　　ព្រះជិនុកនូវមាតា ៗ
ប្រសិនយូរលង់សល់　　សំទឹងដល់កែវ
ឥឡូវនេះស្ដេចជា　　ទុក្ខសង្រែងសង្រែនៅ ៗ
ហេតុនេះសូមប្រោសប្រាន　　ចង់ឲ្យបានបីតាចៅ

មិតមូលមួយលំនៅ     ទើបនឹងគង់ព្រះជន្មា ។

## បទភាគ

ក្សិណក្សត្រយក្ខយន្ត៍     ស្តេចស្តាប់ព្រះពន្ស     ពន្ធកសាស្តា
ព្រមព្រះទ័យក្សាន     មែនមានមេធាវី     អាសូរករុណា
ពេកពន់កន្ទួន ។     ចូមថើបព្រះកេត្រ     បន្ទូលថានាក់
មាសមិត្តស្នេហ៍ស្ងួន     សព្វថ្ងៃចិត្តគា     ស្នេហាសូនគ្រង
ពុំចង់ឲ្យឃ្លង     អន់អាក់ចិន្តា ។     តែថាបើជ្ស
ផុំគ្នាមពិតពុំ     រើសពិចារណា     ដោះទីងថ្ងោះឆ្ងាយ
ក្រោយ ៗ ទៀតណា     នូវកើតទិន្នា     បំណោរបេរឆ្ងាយ ។
មួយសោតបើថា     អាសូរបីតា     បូរបាអតិព្រាយ
ឲ្យហៅអយុកោ     នៅនគរនាយ     មកនឹងនិយាយ
ឲ្យអស់សេចក្តី ។     ទើបពោធិសត្វ     បើកបន្ទូលថាត់
ត្រាស់ប្រើមន្ត្រី     អញ្ជើញបីតា     ថ្ងៃថ្វាធិបតី
ឲ្យស្តេចមកខ្ញី     កុំលង់ឡើយណា ។     កាលនោះអាមាត្យ
ក្រាបលាខ្ញុំញ៉ូខាត     ដល់ហើយវន្ទា     ទូលថាពជបុត្រ
ពិសុទ្ធថ្ងៃថា     ប្រើខ្ញុំករុណា     អញ្ជើញព្រះអង្គ ។
ទៅថ្កានយកក្សា     ឥឡូវនេះណា     ឆាប់ ៗ កុំលង់
ស្តេចទទួនីងនៅ     មើលឆ្ងាវព្រះអង្គ     មានបើនឹងទ្រង់
ព្រះរាជចិន្តា ។     ដៃដេតបក្រៃ     ស្តេចស្តាប់មន្ត្រី

ទូលទើបម្មីមា ប្រដាប់ព្រះអង្គ ពុំលង់ឡើយណា
បរត្រេបដល់នា រេងរតសួស្តី ៗ ដល់ស្រេចស្ដេចថ្វាយ
បង្គំបម៉ាយ ក្បិនក្សត្រអាសុរី ស្ដេចបើកព្រះសូរ
បន្ទូលមកខ្ញី នូវពាក្យមេត្រី ត្រង់រាជបុត្រា ៗ
ថាហៃដេត ឥឡូវនេះហេតុ យើងមានមេត្តា
អាសូរអាណិត អាបត់ឥតខ្មាសណា យើងគិតយើងប្រា
ណាំណាស់ណាចៅ ៗ ចៅរើយប្រាសាទ ប្រសើរស្អាងស្អាត
សឹងមាសស្អិនស្អៅ ថាបើចៅពាន ឡើងបានដល់ទៅ
លុះលើលំនៅ ដូចពាក្យបិតា ៗ យើងនឹងផ្សំផ្សំ
រៀបការតាមក្រំ ដូចចិត្តប្រាថ្នា ឲ្យទៅទូលប្រាប់
សាស័ប្បវិតា ឲ្យក្សត្រទ្វេហា ស្ដេចត្រេចមកហោង ៗ
ដៃដេតក្កបាល ស្ដាប់ព្រះឱង្កា ស្ដេចទូលវិញស្នង
បើព្រះករុណា មេត្តានេះម្ដង
ខ្ញុំសូមពានហោង កុំព្រួយទ័យព្យា ៗ ក្សត្រយក្ខធិបតី
ស្ដេចឲ្យមន្ត្រី ប្រាមប្រាប់យោធា ឲ្យរៀបប្រាសាទ
សំអាតហើយណា នឹងឲ្យបុត្រា ស្ដេចពានឡើងហោង ៗ
លុះបានពេលា ស្ដេចយក្ខការនា តែស្ដេចប្រេង្គង
មន្ត្រីសេនា យោធាពលផង ហែហមអឹងកង
ត្រសង់គ្រប់គ្នា ៗ កាន់គ្រឿងសហស្ស ច្រូងច្រាងដេរដាស

ជាជួយត្រា ឯពោធិសត្វ បុរសសោភា
នូវព្រះបិតា ស្តេចហៅផ្អូន ៗ លុះដល់ប្រាសាទ
ប្រសើរស្អាងស្អាត ដូចព្រះបំណង ក្សត្រយក្ខទ្រទង់
ស្តេចគង់នោះហោង ព្រះបន្ទូលស្នង រាជបុត្រប្រសារ ៗ
ហៃហាកូនកល្យាណ ចូរបាឡើងស្ថាន ប្រាសាទនេះណា
ឲ្យឪពុកយល់ រិទ្ធីពល្វា សោះទឹងសង្ការ
សន្និះសង្ស្យ ៗ ក្បៀនព្រះដៃដេត ថ្វាយបង្គំហេតុ
សេចក្តីអាឡៃ ពុំមានថយថុប កក់កុចព្រះទ័យ
ដល់តិចឡើយនៃ ទទួលអាជ្ញា ៗ ស្តេចចេញប្រាសាទ
ខ្ពស់ពន់សល់ខ្នាត ដាបដល់វិហារ ប្រាំមួយយោជន៍យល់
ឆ្ងាយសល់សោះសា សរសេរនោះណា មួយមែនគួរខ្លាច ៗ
មុនីរតរលោង សឹងប្រែងព្រមផង ឥតអ្នកណាអាច
យល់ហើយស្ញប់ស្ញែង ក្រញែងរូបខ្លាច ក្សត្រាធិរាជ
ពុំភ្ញ័ករញ្ញក ៗ ពុំឃ្លានព្រះជន្ម ឃ្លានតែប្អូនតន់
សង្សារស្នេហា ក្សត្រថ្ងៃកល្យាណ ប្រណិធានសច្ចា
ទេពធីតាម្នា សោឡសនាយនៃ ៗ តេជះសំណាង
សំណូមខ្ញុំសាង នូវនាងនារី កាលអភិសេក
កាលេជាត្តី សូមទេពសួគ៌ថ្ងៃ មែនមានករុណា ៗ
ជួយខ្ញុំឲ្យបាន ឡើងលុះលើស្ថាន ប្រាសាទសោភា

ក្រេបកក្ដួបរិបូណ៌ មូលមួយស្នេហា ទូវនាងប្អូនក្យ
ដូចចិត្តបំណង ៗ ស្ដេចផ្សងតែម្ទោះ អែង៏កាណ្នោះ
អស់ទេព្ដាផង រំជួលក្ដាត់ក្ដៅ ទួរទៅជាមួ្ដង
មីមកអឹងកង ថ្វាយជ័យបេស្ដា ៗ យកដណ្ដើររត់
ផ្គូផ្គងបំបាត់ មិនឲ្យអ្នកណា យល់ដល់មួយឡើយ
ហើយឲ្យក្សត្រា យល់តែឯក្កា ព្រះអង្គឯងហោង ៗ
ស្ដេចយល់ដណ្ដើរ មណីរតន៍ប្រសើរ ដូចព្រះបំណង
ពេញព្រះហឫទ័យ ក្សត្រថ្ងៃបព្រាស់ប្បង កើ្ដកាលនោះហោង
សម្ដេចកជា ៗ ស្ដេចក្រាបវន្ទី លាក្រុងអាសុរី
ហើយចរយាត្រា ឡើងដោយដណ្ដើរ ប្រសើរសោភា
មនុស្សសត្វនានា ស្ងប់ស្ងៀងទីទៃ ៗ ឯអស់យក្ស
យល់ព្រះបេស្ដា ស្ដែងក្ដាត់ហ្មោះនៃ សរសើរឫទ្ធី
បារមីក្សត្រថ្ងៃ ឱអស់ចារ្យក្រៃ បុណ្យបុត្រពំនាំ ៗ
កាលនោះកូបាល ស្ដេចឡើងកណ្ដាល កន្ដោបឯកា
ត្រដួចត្រដុង ផុតបុងនេត្រា នរនាក់ណា ៗ
មៀនមើលមិនយល់ ៗ ហត់ហើយសំកាំង ល្ហិតល្ហៃទន់ទាំង
ស្ពាំងព្រះកាយពល់ ដោយត្រូវព្រះពាយ រិទ្ធីសាយសល់
ស្រងាត់ស្រងល់ ទោទន់កាយា ៗ ហាក់នឹងរបូត
ព្រះហស្ដសំរូត ធ្លាក់ចុះមកណា តេជៈសម្ភា

បុណ្យបារមីតា សម្ដេចពាជា ប្រែព្រះស្វាតី ។
ស្ដេចយកធម៌ជា សង្វេគអនិច្ចា គុណកែវទាំង ៣
គុណព្រះបីតា មាតាក្បិ ផ្ដាំផ្ដែនឥតបី
ឲ្យអន្តរធាន ។ គ្រាន់ផុតព្រះអគ្គ ព្រះស្វាតីគង់
ដូចកាលមុនមាន កម្លាំងកាយពល ផុងផល់ប្រែប្រាន
ទំពាំឡើងបាន តិច ៗ ទៀតទៅ ។ រឹងថប់រឹងហត់
ញាក់ខ្លួនរន្ធត់ សម្លឹងសៀមនៅ ទ្រង់ព្រះកន្សែង
ថ្លឹងថ្លែងហាហៅ ហៅមេប្អូនពៅ ជួយបងរួសរា ។
ឱអគ្គប្អូនមាស បាបបងប្រែប្រាស ប្រែលឹងស្នេហា
នាងនៅទីងបុត្ត ពិសុទ្ធសោភា ប្ដូរចៅរក្សា
អគ្គឲ្យក្រមេកក្សាន ។ នេះបងអាគត លុះដល់ក្ដីស្លាប់ អាសាពុំបាន
នៃបន្ទូលស្និតស្នេ ថ្នមមេកល្យាណ ឱបាបបុរាណ
បរមជាតិ ។ ស្ដេចខ្ញុំនាងណា ខ្ញុំមចិត្តសង្សារ
ប្រសើរស្រស់ស្រី ហើយខ្ញុំទៅបុត្ត ពិសុទ្ធស្ងួត
ឱកូនពីសី សំឡាញ់បិតា ។ អ្នកនៅទីងម្ដាយ
ទោះក្រទោះឆ្ងាយ ទោះថ្លើងថ្ងៃថ្ងា ឥតអ្នកណានៃ
ក្រៅក្រៃនដ៏បា បានៅរក្សា ម្ដាយកុំប្រហែស ។
ឥពុកមានបា ទុកតាំងអាត្មា ណាកូនពិសេស
វេទកាយកម្ម នាយនាំវិទេស ឱកូនពិសេស

ធ្វើម្ដេចនេះម្ដង ៗ ឱបំណាច់អា ពុកបង្កើតបា
បន្ទូលស្នេស្នង មិនមាននៅនិត ផ្ដេកផ្ដិតស្ងួនគ្រង
កំព្រាឃ្លាត់ហោង ឥតញាតិវង្សា ៗ ឱមាសក្មេងនៅ
ព្រាត់ព្រះបោមចៅ ឮយុកោអយុកា ពីទើបសម្រាល
គេរកាលនោះណា ប្រាស់ទាំងបីតា ពិតពុំបានយល់ ៗ
ឪពុកសង្វាត ផ្ដួផ្ដាច់ជនជាតិ តាមមកជួបដល់
ពៀរពីព្រេងនាយ កម្មកាយទសពល បាបអ៊ីមកផ្ដល់
មិនឲ្យជុំគ្នា ៗ អត់ពីឪពុក សំស្ងួនទល់ទុក្ខ
សង្រេងឈើផ្កា ឱអញគិតគ្រប់ ថែថប់ក្ដាត់ណា
ស្មើផ្កាយឱព បង្អៀតហឫទ័យ ៗ ឱឪពុកផ្ញើ
ខ្មោចនេះនៅលើ កូនកែវប្រពៃ លើកសពបូជា
នូវគ្រានេះនែ តាមច្បាប់វិន័យ បូរាណពជា ៗ
ស្ដេចទួញទេវី នូវបុត្តពីសី ផ្ទុកផ្អើសឱព
ស្រែបទើបព្រះអង្គ ទ្រួតទ្រង់សោកា ទៅព្រះមាតា
បីតាដៀលដៃ ៗ ឱអ្នកមានគុណ ៗ គាប់មហាធ្ងន់ ៗ
ពន់ពេកក្រៃ ឥឡូវបុត្រា នេះណាទឹងក្បៀ
ប្រឡៃនាថ្ងៃ នេះឯងហោងណា ៗ ឱអញឯកា
មកស្លាប់បង់ចោល ព្រះគុណថ្លៃថ្លា ដោយកុសលកម្ម
នានាំអាគ្នា ចោះបង់សៀតណា ដែនដីស្រុកអាយ ៗ

ឱបើដឹងដល់ ពីព្រះទសពល ពិសេសពន្រាយ

សំអ្នកនឹងទល់ ទុកសោកសព្វសាយ សំគិតសំស្តាយ

ខ្ញុំជាបុត្រា ៗ សំអ្នកនឹងមក សាក់សួររិះរក

ដោយក្តីស្នេហា មុខមិញមិនយល់ សូន្យសល់សោះសា

សំសោយសោក្កា ទ្រង់ព្រះកន្សែង ៗ ឱកម្មភាគា

កិលេសតណ្ហា គួរគិតគួរឈ្លង គួរប្រែគួរប្រាស

លាកលះលាលែង ព្រោះកិលេសតែង បំពោតសត្វផង ៗ

ក្សត្រថ្ងៃឧត្តម ភ្ញាំងក្តេបហើយខំ ឡើងទៀតទៅហោង

ប្រឹងប្រាណផ្តល់ផ្តាប់ បំប្រប់ជាម្តង ល្ហិតល្ហៃកន្ទង

ផ្លូសផ្លូកាន់កាំង ៗ ទន់ទាំងកាយា សេរេ្ហមេ្លា

អស់ឧត្តំ ទាំងទិព្វបក្ខិន សោតិន្ទ្រិយំ

កាយាពលំ ពោយរឹងពេកពន់ ៗ ខំឡើងទៀតថ្កាន

ទល់ទប់ពុំបាន ញ័រដូចអន្ទ្រិន ភ្ញាំងក្តុកដួលជាប

ស្រពាប់ទូរន់ សោះសូន្យជីពជន្ម នៃអគ្គមហាក្សត្រ ៗ

នៃអ្នកទាំងឡាយ ចូរចាំបរិយាយ ដំណើរព្រះបាទ

ដៃដេតកពជា សុវណ្ណានាងនាដ លំបាកសល់ខ្នាត

ក្នុងសង្សារ ៗ សង្សារនេះឯង ព្រះអង្គទ្រង់ឈ្លង

យល់ទៅអនា គតគិតគួរប្រែ កុំស្នេទីរាំ

យកនិញ្ចូនជា ពុំអ្នកសព្វថ្ងៃ ៗ សត្វណាមើលង៍

ដំណាក់នៅគង់ សង្សារដល់សៃ ពុំដែលលះលាក
បៀសចាកពីភ័យ គឺព្យាធិក្ស័យ ជាតិជរាណា ។
ប្រដូចប្រពាក់ សោប្រួលតែងដាក់ ករកុំសក្ការ
វិតតួអគ្គប្រាន ពុំមានមេត្តា ដូចកលដលសា
លិបលង់ក្សិនក្សៃ ។ ទោះមនុស្សទេព្តា ទាំងឆកាមា
សោឡសព្រហ្មថ្ងៃ ពុំបៀសចាកពី ព្យាធិក្សិនក្ស័យ
រីរូបសព្វថ្ងៃ គួរគិតអនិច្ចា ។ នោះនឹងរន្ដោះ
វដ្ដសង្សារស្មោះ បៀសចាករោគា ផលទាំងនេះបាន
ដ្បិតទានសិលា លុះនូវប្រាជ្ញា អរហត្តប្រពៃ ។
ដូនបំពោះបាន សម្បត្តិនិព្វាន បរមសុខក្រៃ
នីរទុក្ខនីរសោក នីររោគនីរភ័យ គ្រោះកាចចង្រៃ
បៀតបៀនពុំបាន ។ ហៃជនសម្មាយ រូបយើងសឹងស្រាយ
ខ្ញមសារសោតគ្មាន ឧស្សាហ៍ធ្វើបុណ្យ សូត្រមន្តឲ្យទាន
សាងសីលទើបបាន មគ្គផលដូចប៉ង ។ យើងនូវពណ៌នា
ឯអស់យក្សា ចាំប្រាសាទផង យល់ព្រះភូមិន
នរិនច្បាស់ច្បង ដូចដល់ឈ្មោះហោង ភិតភ័យតកមា ។
ខ្ញុះបីខ្ញុះទ្រេ ខ្ញុះរត់ទៅរក ទឹកក្បិតកត្រា
ខ្ញុះហោះបូលទូល ឥស្សូរយក្សា នូវរាជបុត្រា
កាលនោះឯងនៃ ។ ក្សត្រពីរព្រះអង្គ ជ្រាបហើយស្តេចទ្រង់

តកមាកិតភ័យ សឹងហុនស្ដេចហោះ ផ្ទេកផ្ទះឡើងវៃ
រីរាជបុត្រថ្លៃ ទៅទូលមាតា ៗ ឯនាងទេវី
ព្ឋព្រះស្វាមី ស្ដេចឡើងលើប្រា សោកសោតនាងគិត
អាណិតថប់ថា ឱព្រះរាជា ពានរូបនេះម្ដង ៗ
នាងទួញស្មាស្ងប់ ប្រាសប្រាណបំប្រប់ ហេតុឈឺព្រះបង
កាលនោះរាជបុត្រ ពិសុទ្ធស្នេស្នង ស្ដេចដល់ហើយហោង
ទូលព្រះមាតា ៗ នាងព្ភករាជបុត្រ នាងរងស្ងូនស្ងុត
ស្វាតីជាយា ហាក់គេកាត់ថ្លើម ដង្ហើមទេយា
វៀលរុសធុក ឈឺឈៀបខ្វាងត្រៃ ៗ ពុំអាចទល់ទុប
ផល់ផ្លួលសន្ទុប់ ហៀបនឹងក្សិនក្សៃ ឯព្រះពោធិ
សត្វរំលែសសាត្រែ ថ្នមមាតាថ្លៃ ត្រេតព្រះក្ដ្រា ៗ

(ខ្សែ ៦ សន្សើបតែប៉ុណ្ណោះ)

ខ្សែ ៧ ដើម នាងចំប៉ាថៅនឹងរាជបុត្រយំឱប ស្វាមីលុះសន្ទប់

កណ្ដាល ព្រះបាទធម្មិក បានទទួលដំណឹងថា ព្រះរាជបុត្រ

សុគត់ ទើបនាំអគ្គមហេសីលើកទ័ពចេញមកតាមកំពុងយំសោក

តាមផ្លូវស្រាប់តែមានរាជទូតទីពីរមកទូលថា

រាជបុត្ររស់វិញហើយ

ចុង ព្រះបាទសន្ទុរាជា នឹងព្រះនាងកេសណីសង្វៃ

ដោយឃើញឈ្នួញសំពៅយកផ្កាចំប៉ាមាសមកថ្វាយ

ការផ្សាយរបស់

លេខ ៨៨ វិថីអេមេគ្រីន ភ្នំពេញ

ជិតពេទ្យកុន ព្រហ្មបាយ័ន ពីខាងកើតផ្សារ

---

## សេចក្តីជូនដំណឹង

បណ្ណាគារខ្ញុំបាទ មានទទួលបង់គ្រប់សៀវភៅ មានជាព្រះពុទ្ធរូប រូបថតផ្សេងៗ គឺព្រះរូបព្រះករុណា និងសម្តេចសង្ឃនាយកជាដើម និងសៀវភៅធម៌ សៀវភៅរឿង គ្រឿងសរសេរ សង្ឃដិកា នាយា សំបុត្រកំណើត កាតកូនសិស្ស និងសៀវភៅបារាំង-ខ្មែរផ្សេងៗ ជាច្រើនៗ

សូមនិមន្ត និងអញ្ជើញលោកអ្នកចូលជាវទិញ ដោយមេត្រីៗ

បើទិញដុំ យកទៅលក់ទៀត ខ្ញុំគិតរង្វាន់ជូនយ៉ាងគួរសមៗ.

ព.ស. ២៤៩៦ គ.ស. ១៩៥៣

) រោងពុម្ព ភក-ភិ ភ្នំពេញ (

ថ្លៃ ២រ០០